

ការិយាល័យមេធាវីខ្មែរ

LAW OFFICE OF

Stewart H. Lim & Associates

Stewart H. Lim

Main Office

100 Oceangate Blvd., Suite 1200 • Long Beach, CA 90802

(562) 590-7181 FREE CONSULTATION

- Car Accident, Child Support, Immigration, Divorce, Bankruptcy, Living Trust, Defense you in Court





# ខ្មែរប៉ុស្តិ៍ Khmer Post



ឱសថស្ថានខ្មែរថ្ងៃនេះ

Today Pharmacy

2200 E. Anaheim St.#C Long Bach, CA 90804

Tel: (562) 438-2031 • Fax: (562) 438-2031

(2 Blocks East of Cherry Ave.)

Fast and Friendly Service • FREE DELIVERY

Today Pharmacy

- ទទួលយកនៅ Medicare & Medical និង Insurance ។

សូមស្វាគមន៍!



KHMER BILINGUAL BIWEEKLY NEWSPAPER

VOLUME 02 ISSUE 06 January 01st- 15th 2008 ADVERTISING (562) 313-2129 WWW.THEKHMERPOST.COM


# ក្រុងខ្មែរក្រុងជំនួប ជា ស៊ីម & សុខ អាន ក្រោមការរិះគន់

**ដោយ : មាជ សុវណ្ណារ៉ា**

-កាលពីដើម ខែ ធ្នូ ក្នុងដំណើរដ៏ស្ងៀមស្ងាត់មួយរបស់ក្រុមអ្នកដឹកនាំក្រុងខ្មែរ Long Beach ទៅកាន់ប្រទេសកម្ពុជាបំណងជួបសវនាការជាមួយប្រមុខរាជរដ្ឋាភិបាលលោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ។ ខណៈ

(តទៅទំព័រទី២៩)

## ខ្មែរប៉ុស្តិ៍ និងអ្នកគាំទ្រផ្សាយពាណិជ្ជកម្ម!

អារម្ភកថា

-បុណ្យណូអែល (Christmas) និងឆ្នាំថ្មី ឆ្នាំកុរឆ្នាំ២០០៨ ដែលខិតចូលជិតមកដល់នៅសប្តាហ៍ខាងមុខនេះកាសែតខ្មែរប៉ុស្តិ៍ សូមប្រសិទ្ធិពរជ័យសេរីសួស្តីវិបុលសុខ កើតមានចំពោះលោក លោកស្រីដែលជាអ្នកគាំទ្រការដាក់ផ្សាយពាណិជ្ជកម្មនៅលើទំព័រកាសែតខ្មែរប៉ុស្តិ៍ សូមឱ្យជួបតែសំណាងល្អ និងជោគជ័យគ្រប់ភារកិច្ច និងការងារក្នុងផលរបរជួញដូរ ដោយជៀសផុតនូវរឿងរ៉ាវឧបទ្រពចង្រៃជំម្ងឺដង្កាត់ ( តទៅទំព័រទី១២ )



## CAA : ៣២ឆ្នាំ ធ្វើអ្វីខ្លះ ដើម្បីខ្មែរ?

**ដោយៈ មាជ សុវណ្ណារ៉ា**

-"Long Beach ផ្លូវ Anaheim ក្រុងខ្មែរជាទឹកដីដែលខ្ញុំរស់នៅតាំងពីឆ្នាំ ១៩៨១ ដោយពុំដឹងអ្វីទាំងអស់មិនថា អក្សរកខ្វាក់ ឬ A-B ស៊ីទេ និងបញ្ហាទំនាក់ទំនងគ្នាក៏គ្មានទៀត ទាំងប្តីទាំងប្រពន្ធ និងកូនតូច១៧នាក់ បានពិគ្រោះគ្នា ដោយដាក់ចម្ងល់គិតគ្នាថា តើរស់នៅរបៀបម្តេចទៅ បើគ្មានដីស្រែចំការ និងចង់ទៅណាក៏ពុំរួចដោយគ្មានគោ-ក្របីរទេះផងនោះ?!" នេះជាចម្ងល់ និងការគិតកាលពី២៧ឆ្នាំមុនរបស់អ៊ំ ស្រីម្នាក់បាននិយាយប្រាប់ខ្មែរប៉ុស្តិ៍នៅក្នុងពិធីខួប៣២ឆ្នាំរបស់សមាគមខ្មែរនៅទ្វីបអាមេរិក កាលពីពេលថ្មីៗកន្លងទៅនេះ ដោយក្នុងន័យរបស់អ៊ំស្រីចង់និយាយថា តាមរយៈសមាគមខ្មែរមួយនេះ បានបង្ហាត់បង្ហាញ និងនាំផ្លូវដល់គ្រួសារគាត់ ដើម្បីរស់នៅកែប្រែជីវិតទីពីរលើទឹកដីនៃជីវភាព



របាំជូនពរសួស្តីឆ្នាំថ្មី

( តទៅទំព័រទី១០ )


Law Offices of Boroth chay



No Recovery . No Fees !

5199E . Pacific coast Hwy ,ste.206 , Long Beach ,CA 90 804

Tel: (562) 961-0142 . (562) 453-5898

TOP AUTO INSURANCE AGENCY

Free Quote, Low Rates, Why pay more

• LOW COST • LOW DOWN • LOW MONTHLY

AUTO - LIFE - HEALTH - HOME - COMMERCIAL

-រថយន្ត -ជីវិត -សុខភាព -គេហដ្ឋាន -ពាណិជ្ជកម្ម

សូមអញ្ជើញ !



Tiffany Prak

Agent/Broker

Lic.# 0E44334

2760 E. Spring St., Ste 140 • Long Bach, CA 90806

Tel: (562) 989-1800 Cell: (562) 230-5100

FARMERS INSURANCE GROUP

FARMERS INSURANCE

Douglas Horn Agency



License#0B83665



Life Insurance, Home Insurance, Business Insurance, Auto Insurance, Health Insurance, One Stop Service, Bail Bond,

1633 Long Beach Blvd. Suite A •Long Beach, CA 90813

Tel:(562) 591-3100 Fax:(562) 591-3911

STATE FARM INSURANCE

ក្រុមហ៊ុនធានារ៉ាប់រង State Farm

Peter Kong Insurance Agency

License# OD 23345



- Business Liability Insurance
- Auto Insurance
- Home Insurance
- Life Insurance
- Health Insurance
- Apartement Insurance
- Disability Insurance
- Family & Individual Coverage

• ធានារ៉ាប់រងជីវិត

• ធានារ៉ាប់រងសុខភាព

(Notary Public)

2750 E. Spring Street, Suite 201, Long Beach, CA 90806

Tel:(562) 426-9189 Fax:(562) 426-4669


EVA AIR
777-300ER
ក្រុមហ៊ុនអង្គរទេសចរណ៍
Angkor Travel
ការជ្រើសរើសតែមួយគត់សំរាប់ធ្វើដំណើរទៅកាន់ប្រទេសកម្ពុជា
ទទួលបំរើកិច្ចការធ្វើដំណើរក្នុងសហរដ្ឋ និងអន្តរជាតិ ។
តម្លៃសំបុត្រលក់ចុះថ្លៃជាពិសេសសំរាប់ការធ្វើដំណើរក្នុងស្រុកចេញពី ចំណតយន្តហោះ LAX ទៅកាន់គ្រប់ទីក្រុងក្នុងសហរដ្ឋអាមេរិក ។
មានលក់កាតសំរាប់ទូរស័ព្ទជុំវិញពិភពលោក ( លក់ដុំ និងលក់រាយ) ។
ទទួលធ្វើ Re-Entry Permit លិខិតឆ្លងដែន ។
ទទួលធ្វើ Re-Entry Permit ប្រញាប់ជូនភ្លាមៗ!!!
ជួយរកតម្លៃសំបុត្រយន្តហោះថោកជាងគេទៅស្រុកខ្មែរតាមរយៈក្រុមហ៊ុន Eva Air , Cathay Pacific,Malaysia Air , Singapore Air.
តម្លៃពិសេស $810 សូមអញ្ជើញទាក់ទងនាងខ្ញុំ
Tel: (562) 599-0877 , Fax: (562) 599 4758
1569E, Anaheim St.,C Long Beach ,
CA 90813 (កាច់ជ្រុងផ្លូវ Anaheim & Walnut)
Cellphonatic
Wireless Super center
យើងខ្ញុំមានលក់កាតទូរស័ព្ទ និងដាក់បញ្ចូលទឹកលុយទៅក្នុងទូរស័ព្ទដៃ និងទូរស័ព្ទនៅផ្ទះបានភ្លាមៗ!!!
NO CONNECTION FEE !
NO EXPIRATION DATE !
metroPCS
No te limites.
FREE PHONE !!!
តម្លៃត្រឹមតែ $30 ក្នុងមួយខែ !
NOKIA 5300
NOKIA 5200
NOKIA N93
NOKIA N91
NOKIA 6070
NOKIA 6233
NOKIA 6288

# អាណិតស្រុកណាស់

ដោយ : មំម យើន

កាលបើយើងសង្កេតពិនិត្យមើលអំពីសណ្ដានចិត្ត និងចេតនារម្មណ៍នៃជនជាតិនានាទាំងអស់នៅលើពិភពលោកនេះឃើញថា គេសុទ្ធតែផ្ដោតចិត្តផ្ដោតអារម្មណ៍តែទៅលើរឿងប្រទេសជាតិមាតុភូមិគេខ្លាំងណាស់តួយ៉ាងប្រទេស និងជនជាតិយួនយៀកណាម និងជនជាតិថៃជាដើមគេខិតខំប្រឹងប្រែងខ្លាំងណាស់ ។

ទោះបីគេបានចាកចេញពីមាតុភូមិគេ ហើយគេមកស្នាក់រស់នៅប្រទេសក្រៅក៏ដោយ ក៏គេនៅតែគិតគូររួបរួមសាមគ្គីគ្នាស្រឡាញ់គ្នា ដោយរិះរកគ្រប់វិធី និងមធ្យោបាយទាំងអស់ធ្វើយ៉ាងណាអោយកិត្យានុភាពឧត្ដមភាពកិត្តិយសនៃប្រទេសជាតិមាតុភូមិគេបានថ្កុំថ្កើងរុងរឿងខ្ពង់ខ្ពស់ជាភិយោភាព ។ មិនតែប៉ុណ្ណោះធ្វើឱ្យការរីកចំរើនលូតលាស់គ្រប់វិស័យរចនាសម្ព័ន្ធមានដូចជា វិស័យនយោបាយ វិស័យសេដ្ឋកិច្ច វិស័យសង្គម-កិច្ច វិស័យសិក្សាធិការអប់រំ វិស័យវប្បធម៌ វិស័យទេសចរ ជាពិសេសវិស័យពង្រឹងសតិស្មារតីមនសិកាស្នេហាជាតិមាតុភូមិក្នុងការធ្វើឱ្យពូជសាសន៍ជាតិគេមានជំហររឹងមាំឈរនៅលើគោលការណ៍មួយដឹកនាំជនជាតិគេឱ្យបានក្លាយទៅជាអធិរាជដ៏ឧត្តុង្គឧត្ដមមានប្រាជ្ញាឈ្លៀវឆ្លាតមានសម្បត្តិទ្រព្យស្ដុកស្ដម្ភ ដើម្បីឈានទៅដល់ការពង្រឹងពង្រីកឥទ្ធិពលទៅលើជនជាតិដទៃតាមផែនការដែលគេគ្រោងទុក ។

នៅក្នុងហេតុការណ៍ខាងលើនេះ បើកាលណាក្រឡេកមកមើលជនជាតិខ្មែរយើងវិញ ឃើញថា អន់ខ្សោយខ្លាំងណាស់ ពុំឃើញមានលក្ខណៈអ្វីមួយបង្ហាញឱ្យឃើញច្បាស់ថា ជនជាតិខ្មែរនៅក្នុងប្រទេសក្ដីនៅក្រៅប្រទេសក្ដីចេះរួបរួមសាមគ្គីគ្នាជាធ្លុងមួយស្រឡាញ់គ្នាណែនាំគ្នាបង្ហាត់បង្រៀនគ្នា ពិភាក្សាគ្នា ជួយសង្គ្រោះគ្នាជាពិសេសខិតខំបណ្ដុះបណ្ដាលនូវចំណេះចេះដឹងខាងពង្រីកសតិស្មារតីមនសិកាស្នេហាជាតិ ស្នេហាមាតុភូមិ និងសណ្ដានចិត្តដ៏បរិសុទ្ធ ចេះយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមកចេះលើកតម្កើងគ្នា ដោយរិះរកគ្រប់វិធីដើម្បីធ្វើឱ្យមានកិត្យានុភាពឧត្ដមភាព កិត្តិយសកិត្តិនាមនៃជាតិមាតុភូមិខ្មែរយើងឱ្យបានថ្កុំថ្កើងរុងរឿងខ្ពង់ខ្ពស់ឡើងសោះ ដែលជាប្រភពធ្វើឱ្យជាតិមាតុភូមិខ្មែរឈានទៅដល់ការការពារទ្រទ្រង់ថែរក្សាពូជសាសន៍ និងអរិយធម៌ខ្មែរ ដែលមានមកតាំងពីសម័យបូរាណកាលដ៏យូរលង់ឱ្យបានស្ថិតស្ថេរចេរកាលតទៅមុខទៀត ។

ជាពិសេសទៅទៀត បើសិនជាជនជាតិខ្មែរទាំងអស់ទោះបីជាមេដឹកនាំប្រទេសក្ដីជាមន្ត្រីគ្រប់ជាន់ថ្នាក់ក្ដីជាឧកញ៉ាគ្រប់តំណែងក្ដី និងជាប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ក្ដីបានភ្ញាក់រលឹកឡើង ហើយបើកភ្នែក បើកត្រចៀកឱ្យធំសម្លឹងក្រឡេកមើល ហើយផ្ទៀងស្ដាប់ឱ្យឃើញហើយឮថា មានអ្វីខ្លះនៅជុំវិញខ្លួនយើងលើទង្វើ និងការប្រព្រឹត្តិរបស់យើងស្ថិតនៅក្នុងគតិបណ្ឌិតគតិយុត្តិធម៌ សច្ចធម៌ គុណធម៌ ចរិយាធម៌ សីលធម៌ វឌ្ឍនធម៌ល្អប្រពៃពិតប្រាកដមែនឬទេ ?

នៅក្នុងរឿងជាតិមាតុភូមិនេះ ត្រូវស្ថិតនៅលើបុគ្គលិកលក្ខណៈនៃមេដឹកនាំមានតួយ៉ាងមេដឹកនាំប្រទេសជាច្រើនបានធ្វើរួចមកហើយ គឺមាននាយករដ្ឋមន្ត្រី យៀកណាម (តទៅទំព័រទី១២)

# ផ្ទះមួយផ្សារភ្ជាប់ក្ដីស្រឡាញ់ពីវប្បធម៌ខ្មែរ

ដោយ : ស្រី នាថ


អ៊ំ ឆន ម្ចាស់ផ្ទះ

ផ្ទះខ្មែរមួយត្រូវបានគេប្រទះភ្នែកក្នុងលក្ខណៈចំឡែកគួរឱ្យគយគន់នៃចក្ខុអារម្មណ៍របស់អ្នកធ្វើដំណើរកាត់តាមផ្លូវ Presno និងកាច់ជ្រុង Mariposa Street ក្បែរមន្ទីរពេទ្យទាហាន ។ ដែលអ្នកធ្វើដំណើរមិនអាចមិនថាមិនចោលភ្នែកក្រឡេកមើលនោះទេ មិនថាខ្មែរ ឬជនបរទេស ពីព្រោះអ្វីដែលចំឡែកនៅត្រង់ថា ផ្ទះខ្មែរមួយនោះមានការរៀបចំតុបតែងផ្ទះប្លែកភ្នែក ដូចជាធ្វើរូបសំណាកសត្វតោ ឈរត្រឹងនៃពីមុខផ្ទះ ដោយហារ-មាត់បញ្ចេញចង្កូមសំដែងឫទ្ធិអំណាចបំណងការពារម្ចាស់របស់ខ្លួន មិនឱ្យនរណាម្នាក់ទៅបៀតបៀនរូបគេ ឬក៏ម្ចាស់លំនៅដ្ឋាននោះ ។ ហើយអ្វីដែលមានរចនាបថជាវប្បធម៌ខ្មែរក្នុងផ្លូវព្រះពុទ្ធសាសនាទៀតនោះ គេឃើញរូបព្រះកេសព្រហ្មមុខបួនបានដាក់តាំងសង់ភ្ជាប់នឹងបង្គោលរបងថ្មទ្វារផ្ទះ និងក្បាច់របងជាប់ជាលក្ខណៈប្រាសាទបន្ទាយស្រីយ៉ាងរស់រវើកទៀតផង ។


កូនខ្មែរពីរនាក់កំពុងតែថតជាមួយរូបចម្លាក់សត្វតោ

អ៊ំប្រុស ស៊្រុន ឆន អាយុជាង៧០ ផ្លាយបាននិយាយថា កាលដែលគាត់បានកែច្នៃរៀបចំតុបតែងបែបរចនាបថមានសង់រូបតោនៅពីមុខផ្ទះ និងក្បាច់របងជាមួយរូបព្រះកេសព្រះព្រហ្មមុខបួន ដើម្បីលំអរផ្ទះសំបែងក្នុងការផ្សារភ្ជាប់ជីវភាពរស់នៅស្រុកគេទៅនឹងវប្បធម៌ជាតិខ្លួន ជាមួយនឹងអ្នកកាន់សាសនាព្រះពុទ្ធដែលប្រកាន់សីលទានសមាធិ ដើម្បីនាំចិត្តមកនូវព្រហ្មវិហារធម៌ទាំងបួន គឺមេត្តាករុណា មុទិតា និងឧបេក្ខានៃរូបសំណាកព្រះព្រហ្មមុខបួនដែលបានធ្វើសមាធិខាងផ្លូវចិត្តឈានទៅរកអភិញ្ញា៥យ៉ាង ។

អ៊ំឆន និយាយថា មានជនបរទេសជាច្រើន ពេលដែលធ្វើដំណើរឆ្លងកាត់មុខផ្ទះគាត់នៅកណ្ដាលទីក្រុង Presno ភាគខាងជើងរដ្ឋ California ។ ពួកគេតែងតែដឹកសួរនាំរូបសំណាកទាំងនេះ ចំពោះគាត់ពីអត្ថន័យនៃការតាំងសង់ឡើងពីរូបតោព្រះព្រហ្ម ។ ពិសេសពួកអ្នកកាន់សាសនាគ្រីស្ទ (Church) បានចូលទៅផ្សព្វផ្សាយពីសាសនាខ្លួន ដោយមានការដេញដោលពាក្យសំដីគ្នាពីប្រ-យោជន៍នៃសាសនាព្រះពុទ្ធ និងសាសនាគ្រីស្ទ ។ ដោយគាត់ឆ្លងឆ្លើយចោទគ្នានោះ អ៊ំប្រុស ឆន និយាយថា ពួកបរិស័ទគ្រីស្ទចូលចិត្តជិះកង់ ឬដើរគោះតាមផ្ទះបានចាញ់ប្រាជ្ញរបស់គាត់ពីអត្ថប្រយោជន៍នៃទ្រឹស្ដីរបស់ព្រះពុទ្ធដែលប្រកាន់បែបទស្សនៈវិជ្ជាដោយមិនបៀតបៀនសាសនាដទៃ ដោយ

( តទៅទំព័រទី០៧ )














**ទី~តាំង** (Ty Tang)
Speak Khmer, Thai,
Vietmanes, Lao,
Chinese, English
Cell: (562) 787-1306
sales@cabetoyota.com

**កណ្ណថារា~យូ**
(Kan You)
និយាយភាសាខ្មែរនិងអង់គ្លេស
Cell: (562)477-9702
sales@cabetoyota.com

**វុធ~ផូ**
(Vuth C. Pho)
និយាយភាសាខ្មែរនិងអង់គ្លេស
Cell: (562)552-6439
sales@cabetoyota.com

# TOYOTA *CABE*

# នៅក្បែរលោក-អ្នកជានិច្ច!
# គ្មានក្រេឌីត គ្មានបញ្ហា ទទួលកាត់ខែ!


AVALON


CAMRY


CAMRY SOLARA


COROLLA


PRIUS


YARIS SEDAN


YARIS LIFTBACK


MATRIX


TUNDRA


CAMRY HYBRID


TACOMA


FJ CRUISER


4RUNNER


RAV4


HIGHLANDER HYBRID


LAND CRUISER


SEQUOIA


HIGHLANDER


SIENNA

HYBRID SYNERGY DRIVE®

Hybrid Synergy Drive,® powering the Prius, Camry Hybrid and Highlander Hybrid, combines a clean-burning gas engine with an efficient electric motor to deliver excellent fuel economy, low emissions and performance.

# (562) 595-7411 • (800) 576-2223 • Fax: (562) 424-6731

2895 Long Beach Blvd. Long Beach, CA 90813
1/2 MILE SOUTH OF 405 FRWY Se Habla Español
www.cabetoyota.com 1-877-862-2223




# ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

***ដោយៈ ពិន សំខុន*** **(តពីលេខមុន)**

រហូតមកដល់ចុងឆ្នាំ១៩៤៥ ប្រទេសកម្ពុជាបានទទួលការគ្រប់គ្រងយ៉ាងច្របូកច្របល់រកយល់មិនបាន។ មុនពេលបារាំងមកដល់កម្ពុជានៅក្នុងនៅក្នុងកណ្តាប់ដៃសៀមពាក់កណ្តាល នៅកណ្តាប់ដៃយួនពាក់កណ្តាល ស្តេចខ្មែរនាពេលនោះពុំមានឯករាជ្យសំរាប់គ្រប់គ្រងនោះទេ។ នៅពេលបារាំងមកដល់ក៏បានវាត់ឯករាជ្យពីប្រទេសជិតខាងទាំងពីរ ឱ្យមកខ្មែរម្តងបន្តិចៗមកវិញ ដោយសន្ធិសញ្ញាបារាំង និងប្រទេសជិតខាងទាំងពីរនោះ ក៏ប៉ុន្តែចលនាទាមទារឯករាជ្យពីបារាំង បានប្រព្រឹត្តទៅច្រើនដងគួរឱ្យបារម្ភដោយបញ្ញវ័ន្តខ្មែរ ។

សង្គ្រាមលោកលើកទីពីបានមកដល់កម្ពុជា ឆ្នាំ១៩៤០ នៅពេលខ្មែរកំពុងបង្កើតអ្នកចេះដឹង ដោយការរៀបចំស្ថាប័នសម័យថ្មីសំរាប់គ្រប់គ្រង ក៏ប៉ុន្តែដោយសារចលនាស្អប់បារាំង ព្រះបរមរាជវាំង និងរដ្ឋាភិបាលខ្មែរ បានចាប់យកជាសម្ព័ន្ធមិត្តជប៉ុនដែលជាអ្នកខ្លាំងនៅពេលនោះ គឺនៅពេលនោះឯងដែលបារាំងដែលជាសម្ព័ន្ធមិត្តរបស់ជប៉ុនដែរនោះ កាត់ដីខ្មែរមួយភាគបីខាងជើងឱ្យទៅសៀម។

នៅដំណាក់កាលសង្គ្រាមនេះ កម្ពុជាបានផ្តើមប្រើរូបមន្តនៃការគ្រប់គ្រងបែបថ្មី ដោយប្រើសមត្ថភាពអ្នកចេះដឹងខុសពីពេលមុនៗ ដែលគេប្រើមនុស្សទុកចិត្តស្គាល់គ្នា ដោយប្រើច្បាប់ដែលសរសេរខុសពីពេលមុនដែលច្បាប់ គឺជាពាក្យត្រាស់បង្គាប់ដោយព្រះរាជា ឬស្តេចក្រាញ់ ដោយប្រើមធ្យោបាយសម្រាប់គ្រប់គ្រងមានសេដ្ឋកិច្ច មានការទូត មានអប់រំ ។ល។ ដែលពីមុនមកមានតែមហាមន្ត្រី ឬចៅហ្វាយខេត្តទេ ដែលមានតួនាទីទាំងនោះក្នុងការបំរើព្រះរាជាដោយផ្ទាល់ ។ រដ្ឋាភិបាលបីនៃរូបមន្តថ្មីនេះ បានត្រូវបង្កើតឡើងជាដំបូងបង្អស់នៅឆ្នាំ១៩៤៥ ដែលពីរនៅក្នុងរបប "ជប៉ុនព្រះអាទិត្យរះ" ហើយចុងក្រោយ នៅពេលចប់សង្គ្រាមហើយបារាំង "សេរី " កាន់កាប់ជំនួសរបប "បារាំងវីស៊ី" វិញ តែទាំងបីនោះសុទ្ធតែជ្រើសរើសដោយការតែងតាំងទាំងអស់។

**រាជានិយមផ្តាច់ការក្នុងក្របខ័ណ្ឌនៃការកាន់កាប់ត្រួតត្រារបស់ជប៉ុន (១៩៥៤):**

***១-រដ្ឋាភិបាល នរោត្តម សីហនុ ១៨.៣.១៩៤៥-១៣.៨.១៩៤៥)***

- -នាយករដ្ឋមន្ត្រី : នរោត្តម សីហនុ
- -រដ្ឋមន្ត្រីហិរញ្ញវត្ថុ : អ៊ឹង ហ៊ី
- -រដ្ឋមន្ត្រីសេដ្ឋកិច្ចជាតិ :នរោត្តម ម៉ុងតាណា
- -រដ្ឋមន្ត្រីអប់រំជាតិ និងឃោសនា : មាស ណាល់
- -រដ្ឋមន្ត្រីការពារជាតិ និងផ្គត់ផ្គង់ : ទា សាន
- -រដ្ឋមន្ត្រីយុត្តិធម៌ : ច័ន្ទ ណាក
- -រដ្ឋមន្ត្រីមហាផ្ទៃ និងកិច្ចការនយោបាយ : ស៊ុម ហេង
- -រដ្ឋមន្ត្រីធម្មការពុទ្ធិក : សិក្សា និងវិចិត្រសិល្បៈ : វ៉ា កាមែល
- -អគ្គសេនាធិការ : នង គីមនី
- -អនុរដ្ឋមន្ត្រីអប់រំជាតិ : ជន ហ៊ល

***២. រដ្ឋាភិបាលសឺនង៉ុកថាញ់ (១៤.៨.១៩៤៥-១៦.១០.១៩៤៥)***

- -នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេស : សឺន ង៉ុកថាញ់
- -រដ្ឋមន្ត្រីក្រសួងកសិកម្ម : នរោត្តម ម៉ុងតាណា
- -រដ្ឋមន្ត្រីមហាផ្ទៃ : ស៊ុម ហេង
- -រដ្ឋមន្ត្រីធម្មការ-ពុទ្ធិក : សិក្សា និងវិចិត្រសិល្បៈ : វ៉ា កាមែល
- -រដ្ឋមន្ត្រីសេដ្ឋកិច្ចជាតិ និងផ្គត់ផ្គង់ : ប៉ាច ឈឺន
- -រដ្ឋមន្ត្រីយុត្តិធម៌ : ពីទូដឺម៉ុងតេរ៉ូ
- -រដ្ឋមន្ត្រីការពារជាតិ-សាធារណៈការ និងសុខាភិបាល : ឃឹម ទិត
- -រដ្ឋមន្ត្រីអប់រំជាតិ : ញឹក ជូឡុង
- -រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ : ប៉ែន នុត

### ផ្ទះមួយផ្សារភ្ជាប់ក្តីស្រឡាញ់....

សុំម្យ៉ាងឱ្យមនុស្សលោកធ្វើអំពើល្អប្រកាន់មេត្តាធម៌ដាក់ក្នុងខ្លួនកុំចងកម្ពពារនឹងអ្នកដទៃ ។

គេធ្លាប់ជួបប្រទះឃើញរូបសំណាកសត្វតោនៅតាមទីវត្តអារាមនៃក្លោងទ្វារវត្ត ឬក្លោងទ្វារព្រះវិហារ និងស្ពានបុរាណនានា ក្នុងលក្ខណៈលំអរសោភ័ណភាព ដើម្បីភ្ជាប់ការស្រឡាញ់រវាងមនុស្ស និងសត្វ ប៉ុន្តែតំណរតមកពីបរមបុរាណកាលមកគ្មានប្រភពណាច្បាស់ថា សត្វតោមានប្រយោជន៍អ្វីសំរាប់មនុស្សឬទេ បានជាចាស់បុរាណពេលដែលសង់ព្រះវិហារ ស្ពាន និងប្រាសាទក្តីតែងតែភ្ជាប់នូវរូបសំណាកតោនេះឡើង ក្នុងលក្ខណៈជាប្រវត្តិសាស្ត្រផ្នែកវប្បធម៌សាសនាខ្មែរតរៀងមក ។

អ្នកណាក៏ដឹងផងដែរថា សត្វតោ ឬរាជសីហ៍ជាសត្វកាចសាហាវ (ស្តេចសត្វ) ដែលឱ្យគេកាត់ស្មានថា មូលហេតុដែលចាស់ៗបុរាណបាននាំគ្នាធ្វើរូបសំណាកតោនេះឡើង គឺប្រហែលជាគេគិតថា នៃសម័យដ៏យូរលង់កន្លងមកតាមទីវត្តអារាម ឬប្រាសាទក្តីមានភាពល្អរល្វេវគ្មានរបង ឬរនាំងការពារសត្វកាចសាហាវផ្សេងៗ ដើម្បីការពារខ្លួននោះពួកចាស់ៗបុរាណបានធ្វើរូបសំណាកសត្វតោនេះឡើង ដើម្បីបន្លាចឱ្យសត្វដទៃមានការខ្លបខ្លាចឥទ្ធិពលសត្វតោ ឬរាជសីហ៍ដែលជាស្តេចសត្វនោះ ដែលមិនហ៊ានមកជិតទីកន្លែងសក្ការៈ ឬលំនៅដ្ឋានរបស់ពួកគេ ។

និយាយពីសត្វតោ ធ្វើឱ្យយើងគ្រប់ៗគ្នាដែលមានមនោ-



សញ្ចេតនានៃបទចម្រៀងអធិរាជសម្លេងមាស ស៊ីន ស៊ីសាមុត បានផ្តោះផ្តងសេចក្តីស្នេហានៃយុវវ័យពីររូបនៅខេត្តបាត់ដំបង ។ គូស្នេហ៍ទាំងពីរនោះបានយកតោថ្មទាំងពីរនោះ ដោយយកតោថ្មមួយគូរដែលឈរសងខាងក្បែរស្ពានថ្មឆ្លងកាត់ស្ទឹងសង្កែធ្វើជាសាក្សីនៃភក្តីស្នេហ៍ស្មោះស្ម័គ្រនឹងគ្នា ដោយគ្មានកិច្ចកែប្រែឡើយ ។ ដែលអត្ថន័យ និងអត្ថរសនៃបទចម្រៀងយើងរកឃើញថា មនុស្ស និងសត្វត្រូវតែភ្ជាប់និស្ស័យនឹងគ្នា ដូចជា ស្តេចប្រដាល់ ម៉ៃថៃសាន់ បានចិញ្ចឹមសត្វខ្លានៅជាមួយ ហើយពួកអ្នកលេងសៀកនៅ Holly Wood នៃតំបន់អូស្ត្រាលីយ៉ាងដូច្នេះផងដែរ ។/

MAYURAVIDEO

## ហាងមយូរាវីដេអូ (Mayura Video)

*ក្រុមហ៊ុន មយូរា បានបើកហាងលក់វាយនិងជួលកុនមយូរា ជូនភ្ញៀវដោយខ្លួនឯងផ្ទាល់ចាប់តាំងពីថ្ងៃនេះតទៅហើយនៅទីក្រុងLong Beach ក្នុងតម្លៃថោកសមរម្យ ។*

១- **មយូរាវីឌីអូ** *(MAYURA VIDEO)*

1295 E. Anaheim Street. Long Beach, CA 90813
Tel: (562) 818-0863 • (562) 761-3515

*(កាច់ជ្រុង* Anaheim Street & Orange Avenue *ជិតភោជនីយដ្ឋាន* ROSEMANEE *និងទល់មុខភោជនីយដ្ឋានហាងសួគ៌ថ្មី) ។*

*២- M.L.K MARKET*

1821 Martin Luther King Avenue. Long Beach, CA 90806 • Tel: (562) 591-4295
*(ជិតកាច់ជ្រុង* Martin Luther King & Pacific Coast Hwy. *ម្ខាងផ្លូវផ្សារអ៊ីង) ។*

*ហាង MAYURA VIDEO មានលក់វាយនិងជួលDVD របស់ក្រុមហ៊ុនផ្សេងៗផងដែរ ។*

**សូមអញ្ជើញដោយមេត្រីភាព ពីក្រុមហ៊ុនមយូរាយើងខ្ញុំ!**

ហាងខ្មែររដ្ឋជួសជុលរថយន្ត

RATH SHOP

RACHE´S AUTO SERVICE

State and Emission Inspetion
General Repair and Maintenace



5105 N.2ND ST.
PHILADENPHIA, PA 19120
TEL: (215) 320 - 2418
FAX: (215) 329 - 2419

RATH
CELL: (215 ) 431 - 6376

# ព្រឹត្តិការណ៍ថ្ងៃ៧មករា និងការកាត់ទោសខ្មែរក្រហម


ហ៊ុន សែន


ប៉ុល ពត


ខៀវ សំផន


តាម៉ុក

***ដោយ : ម៉ម យ៉ឺន***

នៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលដែលមាននាយករដ្ឋមន្ត្រីជាអតីតខ្មែរក្រហមដែរ បានចាប់ផ្តើមប្រកាសបើកសម័យប្រជុំកាត់ទោស ដែលគេឱ្យឈ្មោះថា "តុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម" ។

- តើខ្មែរក្រហមជាអ្នកណា ?
- តើអ្នកណាជាមេខ្មែរក្រហម ?
- តើហេតុអ្វីបានជាគេបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ?

-តើហេតុអ្វីបានជាទើបតែមានតុលាការកាត់ទោសមេខ្មែរក្រហមនៅពេលនេះ ម្តេចក៏មិនបង្កើតតុលាការកាត់ទោសនេះ តាំងតែពីឆ្នាំ១៩៧៩ មក? ដែលជាឆ្នាំពួកមេខ្មែរក្រហមត្រូវចាញ់ធ្លាក់ពីអំណាចរួចហើយ ក្រុមខ្មែរក្រហមថ្មីមួយទៀត ដែលបានប្រឆាំងនឹងខ្មែរក្រហមបានទទួលជ័យជំនះ បានកាន់អំណាច រហូតមកដល់សព្វថ្ងៃនេះ ។

បើតាមការតាមដានពិនិត្យមើលនៅក្នុងរឿងរ៉ាវរបស់ក្រុមខ្មែរក្រហមនេះ ឃើញថា ក្រោយពីបានជ័យជំនះលើសាធារណរដ្ឋខ្មែរ ដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ នឹងទ្រង់សិរិមតៈ កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មកក្រុមខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យនេះ បានកាន់កាប់អំណាចគ្រប់គ្រងប្រទេសខ្មែរពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦ មានសម្តេចនរោត្តម សីហនុ ធ្វើជាប្រធានាធិបតី ។ ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៨ មានលោក ខៀវ សំផន ធ្វើជាប្រធានគណៈប្រធានរដ្ឋ. លោក ប៉ុល ពត ហៅសាឡុតស ជាប្រធានបក្សប្រជាជនបដិវត្តន៍កម្ពុជា ហើយនឹងមានវិរៈជនសំខាន់ៗដទៃទៀតទាំងស៊ីវិលទាំងទាហាន ។

នៅក្រោមការគ្រប់គ្រងខ្មែរក្រហមជីវិតប្រជាពលរដ្ឋខ្មែរប្រមាណជិត២លាននាក់ ត្រូវបាត់បង់ដោយសារតែការសម្លាប់យ៉ាងសាហាវឃោរឃៅបំផុត ដែលមតិជាតិ និងអន្តរជាតិចាត់ទុកក្រុមនេះថា ជាឃាតករប្រល័យពូជសាសន៍មានន័យថា ក្រុមនេះមានគម្រោងផែនការចង់សម្លាប់ពូជសាសន៍ខ្មែរ អោយស្លាប់រលាយសាប់សូន្យអោយអស់ពីលើទឹកដីខ្មែរទាំងមូល ។

លុះមកដល់ចុងឆ្នាំ១៩៧៨ ស្រាប់តែមានកងទ័ពយួនយៀកណាមប្រជាធិបតេយ្យចំនួនប្រមាណពីរសែននាក់ មានអាវុធយុទ្ធភណ្ឌគ្រប់ធុន ជើងគោក ជើងទឹក ជើងអាកាស ព្រមទាំងអ្នកជំនាញការ និងទីប្រឹក្សាជាច្រើនពាន់នាក់ បានចូលវាយលុកលុយប្រទេសខ្មែរដេញកំចាត់ក្រុមខ្មែរ ក្រហមកម្ពុជាប្រជាធិបតេយ្យតែក្នុងរយៈពេលប្រមាណពីរសប្តាហ៍ប៉ុណ្ណោះ កងទ័ពយួនយៀកណាមបានទទួលជ័យជំនះកាន់កាប់ប្រទេសខ្មែរទាំងមូល ។

បន្ទាប់មកកងទ័ពយួនប្រជាធិបតេយ្យបានលើកតែងតាំងក្រុមខ្មែរក្រហមមួយក្រុមថ្មីទៀត មានឈ្មោះ ប៉ែន សុវណ្ណ, ហេង សំរិន, ជា ស៊ីម, ហ៊ុន សែន អោយ ធ្វើជាមេដឹកនាំគ្រប់គ្រង ដែលអមដោយក្រុមប្រឹក្សា

(តនៅទំព័រទី១៣)

ចំណងដៃពិសេសពីផលិតកម្មមាតុភូមិ

ភូមិយើង OUR VILLAGE Production

មាតុភូមិ MIETOPHOUM

2517 E. ANAHEIM STREET LONG BEACH, CA 90804
Tel: (562) 968-7188 • (562) 438-8602




CD 1 & CD 3 ON SALE NOW

កម្រង CD អធិរាជសម្លេងមាសអមដោយអត្ថាធិប្បាយ លេខ១ & ៣ បានចរាចរនៅលើទីផ្សារហើយ!

ផលិតកម្មមាតុភូមិ សូមស្វាគមន៍ !

# លោក ហ៊ុន សែន ព្រមានមន្ត្រីគណបក្សប្រឆាំង



ហ៊ុន សែន

**ដោយ : ប្រសិទ្ធ**

លោក ហ៊ុន សែន បានគំរាមជាសាធារណៈទៅលើមន្ត្រីជាន់ខ្ពស់មួយរូបនៃគណបក្សប្រឆាំងថា ប្រយ័ត្នខ្ញុំផ្សព្វផ្សាយខ្សែអាត់ និងឯកសារឱ្យសាធារណៈជនបានដឹង ។ លោក ហ៊ុន សែន បានមានប្រសាសន៍បែបនេះកាលពីថ្ងៃពុធ ទី១៩ ខែធ្នូ ឆ្នាំ២០០៧ នៅក្នុងពិធីសម្ពោធប្រឡាយទឹកមួយខ្សែដែលបានជំនួយឥតសំណងរបស់ជប៉ុនអំពីអតីតកូនចារកម្មរបស់លោកនោះ គឺថាគណបក្សប្រឆាំងមួយរូបដែលមានតួនាទីសំខាន់ថែមទៀត ។

លោក ហ៊ុន សែន មានប្រតិកម្មជាខ្លាំងចំពោះការរិះគន់ទៅលើរដ្ឋាភិបាលអំពីតម្លៃប្រេងសាំង ដែលមានតម្លៃខ្ពស់ បើធៀបទៅនឹងប្រទេសជិតខាងបន្ថែមលើនេះទៀតនោះ គឺរឿងដែលទាក់ទងទៅនឹងលោក ហ៊ុន ម៉ាណែត ដែលជាកូនប្រុសរបស់លោក ហើយអ្នកដែលលោកគំរាមនោះ ត្រូវគេសង្ស័យនោះ គឺជាលោក សុន ឆ័យ ។ លោក សុន ឆ័យ ក៏បានឱ្យដឹងដែរថា "ការរិះគន់ទាំងឡាយហាក់ដូចជា ធ្វើឱ្យលោក ហ៊ុន សែន ទទួលយកមិនបាន " ហើយលោកបន្តទៀតថា "យើងដឹងហើយថា សម្តេចយើងមានកលល្បិចច្រើនណាស់ ក្នុងការការពារអំណាចរបស់គាត់ ហើយរូបលោកផ្ទាល់ក៏មិនមានការបារម្ភចំពោះបញ្ហាសុវត្ថិភាពរបស់លោកឡើយ ។/


**Unipaq Realty & Financial**

Complete Real Estate Services

សូមអញ្ជើញដោយមេត្រីភាព !

*-បំរើកិច្ចការទិញលក់ដូរទិញផ្ទះទូទៅ*

*-អ្នកប្រឹក្សាពិគ្រោះយោបល់នៃការខ្ចីប្រាក់*



**David Kuoch**

*Real Estate Agent*

*Loan Consultant*

Cell: (714) 351-2803
Office: (714) 892-2070
Fax: (714) 893-2059
Residence: (714) 774-4061
12062 Valley View St., Suite 204B
Garden Grove, CA 92845
Email: davidkuoch@sbcglobal.net



**ក្រុមតន្ត្រីសោភារី**

Sopheary Band

រីករាយបំផុតក្នុងការប្រគំតូរ្យតន្ត្រីជូនលោក-អ្នកក្នុងពិធីបុណ្យផ្សេងៗ ។
សូមទាក់ទងអ្នកគ្រប់គ្រង :

**Charlie Ouk 562-591-2011**
**Cell: 562-400-7678**





# សមាគមខ្មែរនៅអាមេរិក

# CAMBODIAN ASSOCIATION OF AMERICA

## A Nonprofit Human Services Organization

2 Hearts, 2 Hands, 1 Purpose: Building a Strong, Healthy Marriage

## លំនាំសុភមង្គលនៃស្វាមីភរិយា និងគ្រួសារ

***តពីលេខមុន***

ឧបសគ្គមានច្រើន ដូចជា ភាសា ចំណីអាហារ សំលៀកបំពាក់ ជំនឿសាសនា ការថែទាំសុខភាព និង ការអប់រំ ។

**ដំណើរផ្លាស់ប្តូរនៃជីវិត**

**ក្នុងបឋមវ័យ**

កុមារត្រូវតែទទួលស្វាគមន៍ចូលរួមក្នុងសង្គមគ្រួសារ និងសហគមន៍ ហើយត្រូវតែបានទទួលនូវបរិយាកាសប្រកបដោយសុវត្ថិភាព និងភាពកក់ក្តៅ ។ ពួកគេគួរត្រូវទទួលការបង្រៀនឱ្យដឹងថា : ពួកគេមានគោលគំនិតល្អៗ ដោយយោងទៅតាម សញ្ជាតិ វប្បធម៌ និងការឱ្យតម្លៃនៃគ្រួសារ ។

**ការងារចាំបាច់ក្នុងរយៈពេលចុងក្រោយរបស់កុមារភាព :**

កូនក្មេងត្រូវទទួលការបង្រៀនឱ្យចេះយកចិត្តទុកដាក់ចំពោះអ្នកដទៃ ព្រមទាំងចេះដោះស្រាយបញ្ហាខ្លួនឯងនៅក្នុងសហគមន៍ដ៏ធំធេង ។ សង្គមគ្រួសារ និងសហគមន៍ក៏ត្រូវត្រៀមខ្លួនជាស្រេច ដើម្បីបង្ហាត់បង្រៀនគេឱ្យចេះមានការទទួលខុសត្រូវនិងសិទ្ធិគ្រប់បែបយ៉ាងក្នុងដំណើរជីវិតឈានចូលយុវវ័យរបស់គេ ។

**វ័យកណ្តាល (មជ្ឈិមវ័យ)**

យើងគប្បីតាំងខ្លួនជាគ្រូបង្រៀន អ្នកទទួលខុសត្រូវ និងជាអ្នកថែទាំអប់រំដល់អ្នកទាំងឡាយណាដែលនៅក្មេងជាងយើង ។ គឺរយៈនេះហើយដែលយើងត្រូវរៀនចេះសំរបសំរួលបត់បែនតាមសេចក្តីត្រូវការរបស់ក្មេង ។

**វ័យចំណាស់ (ព្រឹទ្ធវ័យ)**

ត្រូវរៀបចំបន្តវេនដល់ក្មេងជំនាន់ក្រោយនូវរឿងរ៉ាវ និងមេរៀនល្អៗនៃគ្រួសារ វប្បធម៌ ប្រពៃណី របស់យើងដោយមានចិត្តអំណត់ធន់ និងសេចក្តីអធ្យាស្រ័យ ។

**ការរួមរស់នៅជាមួយគ្នាមុនពេលរៀបអាពាហ៍ពិពាហ៍ក្នុងសហរដ្ឋអាមេរិក**

ប្រទេសអាមេរិកមានអត្រាខ្ពស់ណាស់ក្នុងការរួមរស់ជាមួយគ្នាមុនពេលរៀបអាពាហ៍ពិពាហ៍ តើការរស់នៅបែបនេះ អាចជួយបន្ថយនូវការលែងលះគ្នាឬទេ ? គ្មានភស្តុតាងណាមួយអាចបញ្ជាក់ថា : ការរស់នៅជាមួយគ្នាមុនពេលរៀបការអាចកាត់បន្ថយដល់ការលែងលះគ្នានោះទេ ។ ការស្រាវជ្រាវភាគច្រើនបាននិយាយថា : គូភាគីរស់នៅជាមួយគ្នាមុនពេលរៀបការក៏នៅតែមានការលែងលះបែកបាក់គ្នាដ៏គួរឱ្យកត់សម្គាល់ផងដែរ ។

**សេចក្តីត្រូវការនៃគូស្រករ និងគ្រួសារឆ្ពោះទៅរកសុភមង្គល**
**(Healthy Marriage Requires)**

- -ការទាក់ទងគ្នាដោយប៉ិនប្រសប់
- -ការគោរពគ្នាទៅវិញទៅមក
- -ការទុកចិត្តគ្នា
- -ការយល់ដឹងគ្នា
- -ដំណោះស្រាយនៃវិបត្តិ
- -ការព្រមព្រៀងគ្នា
- -ការទទួលខុសត្រូវ
- -ការរៀបគំរោងថវិកាសំរាប់គ្រួសារ
- -មុខងារប្តី-ប្រពន្ធ-កូន

ជាទូទៅគូស្រករដែលមានការយល់ឃើញដូចគ្នាចំណូលចិត្តដូចគ្នា និងចរិកឥតដូចគ្នានឹងធ្វើឱ្យប្តីប្រពន្ធគូរស្នេហ៍ និងគ្រួសារប្រកបដោយភាពមាំមួនហ្នឹងហ្ន ។

**តទៅលេខក្រោយ**

# C.A.A: ៣២ឆ្នាំ ធ្វើអ្វីខ្លះ...

ថ្មី ដែលមើលទៅពិភពលោកមានភាពភ្លឺស្វាងជីវភាពគ្រួសាររស់ក្នុងភាពប្រសើរកូនៗទាំង៧នាក់បញ្ចប់ការសិក្សាថ្នាក់ខ្ពស់មានការងារល្អៗ មិនថា កិច្ចការរដ្ឋការ ឬឯកជនក្រុមហ៊ុនឡើយ ។ អ៊ំស្រីសារីបន្តថា សមាគមខ្មែរមួយនេះបានជួយអភិវឌ្ឍន៍សមាគមខ្មែរយើងឱ្យមានការជោគជ័យក្នុងជីវិតយើងច្រើនណាស់ ។


ចៅសង្កាត់ Dee Andrew


អគ្គនាយករាយការណ៍ពីសកម្មភាពការងារឱ្យភ្ញៀវស្តាប់


អគ្គនាយក CAA គុជ គីមថៃ


ប្រធានក្រុមប្រឹក្សាភិបាល CAA Pin thuy Tim

-កាលពីសប្តាហ៍ទី១ ខែធ្នូ ឆ្នាំ២០០៧ សមាគមខ្មែរនៅទ្វីបអាមេរិក (C.A.A) បានជួបជុំគ្នាប្រារព្ធខួបទី៣២ ឆ្នាំ ដែលមានកំណើតចាប់តាំងពីឆ្នាំ១៩៧៥ នៅលើទឹកដីសហរដ្ឋអាមេរិក ។ ស្របពេលដែលស្ថានការណ៍នយោបាយនៅកម្ពុជាកំពុងស្ថិតនៅក្នុងគ្រោះអាសន្ននៃរបបកាប់សម្លាប់ប្រល័យពូជសាសន៍ពីពួកខ្មែរក្រហមកាន់កាប់ដែលបានផ្តាច់ផ្តិលជីវិតមនុស្សអស់ជិត២លាននាក់ ។ ហើយក៏ជាឆ្នាំដែលរបបសាធារណរដ្ឋខ្មែររបស់សេនាប្រមុខ លន់ នល់ បានដួលរលំធ្វើឱ្យអ្នកនយោបាយខ្មែរសម័យនោះមិនថា ទាហានរដ្ឋការ ឬបញ្ញាវ័ននិស្សិតត្រូវភៀសខ្លួនមកកាន់សហរដ្ឋអាមេរិកជាង ៧០០០នាក់ ជាដំបូងនៅលើទឹកដីអាមេរិក ។ ដែលអ្នកទាំងអស់នោះហើយបានផ្តួចផ្តើមគំនិតគ្នាបង្កើតនូវសមាគម ឬអង្គការដើម្បីសង្គ្រោះជនភៀសខ្លួនខ្មែរបន្តវេងគ្នាមកក្រោមជំនួយថវិកាពីសហរដ្ឋអាមេរិក ឬសហប្រជាជាតិ និងអង្គការជំនួយធំៗក្តី ។

-ក្នុងពិធីរំលឹកខួបខួនគំរប់៣២ឆ្នាំ ដែលមានរបាំបុរាណខ្មែរដែលកូនខ្មែរកើតនៅទីនេះរាំឡើងក្នុងកាយវិកាក្បាច់ពត់ពេនដៃទន់ល្វើយ ដើម្បីជូនពរដល់ភាពជោគជ័យនៃបេសកកម្មរបស់មុនស្សម្នាក់ៗ និងក្រោមក្រសែភ្នែកភ្ញៀវចូលរួមរាប់រយនាក់ លោកអគ្គនាយកសមាគមខ្មែរនៅទ្វីបអាមេរិក គុជ គីមថៃ ថ្លែងថាសមាគមខ្មែរមួយនេះនៅតែរក្សាឋានៈជាសមាគមខ្មែរមិនរកកម្រៃ (Non Profit) ដ៏ធំជាងគេ និងមានវ័យចំណាស់ជាងគេ ក្រោមស្ថេរភាពថវិកាហ្នឹងហ្នំក្នុងរយៈពេល៣២ឆ្នាំកន្លងទៅនេះ ដល់ការបំរើសេវាកម្មប្រជាជនភៀសខ្លួនខ្មែរ និងជាតិសាសន៍ដទៃទៀត ។

-អគ្គនាយក គីមថៃ គុជ បន្តសំដីថា យើងបានធ្វើសកម្មភាពការងារក្នុងគម្រោងជាមួយសមាគមខ្មែរ៥០%, ១៥%ជាមួយជនជាតិអាស៊ីមាន : លាវ, វៀតណាម, សាមន, រី ១៥%ជាជនជាតិស្ពែនីស, ១០%ជាជាតិសាសន៍ស្បែកខ្មៅ និង១០%ជាអាមេរិកកាំងស្បែកស ។

-នៅក្នុងរបាយការណ៍គេឃើញមានសកម្មភាពដែលសមាគមមួយនេះនាំយកទៅអប់រំ ឬហ្វឹកហ្វឺនបងប្អូនខ្មែរ ឬចម្រុះសាសន៍ដទៃទៀតនោះមានកម្មវិធីថែរក្សាសុខភាព, ទ្រទ្រង់សុភមង្គលគ្រួសារ និងអាពាហ៍ពិពាហ៍, ជួយបង្រួបបង្រួមគ្រួសារ និងថែរក្សាកូន, កម្មវិធីបង្រៀនភាសាអង់គ្លេស និងភាសាខ្មែរ, ការលូតលាស់របស់ក្មេងតូចៗ, កម្មវិធីអប់រំកូន, អន្តរាគមន៍អំពើហឹង្សា ឃោឃៅក្នុងគ្រួសារ, កិច្ចការពារ, ការរំលោភបំពាន និងការធ្វេសប្រហែសបណ្តែតបណ្តោយក្មេង, កម្មវិធីព្យាបាលការញៀនសុរា និងគ្រឿងញៀន, ជួយមនុស្សចាស់ជរាអភិវឌ្ឍន៍ក្មេងវ័យជំទង់រួមនឹងកម្មវិធីថែរក្សារបាំ-វប្បធម៌ជាដើម ។ ដែលកម្មវិធីនេះ ត្រូវមន្ត្រីសមាគមអះអាងថា បើបងប្អូនខ្មែរមានបញ្ហានៅក្នុងគ្រួសារពាក់ព័ន្ធនឹងកម្មវិធីខាងលើសូមមករកដំណោះស្រាយជាមួយគ្នា ដើម្បីអភិវឌ្ឍន៍សមាគមខ្មែរយើង ។

-អគ្គនាយក គុជ គីមថៃ ថ្លែងថា ក្នុងឆ្នាំ២០០៧នេះ សមាគមបានផ្តល់កិច្ចការងារដល់បុគ្គលិកថ្មីចំនួន ៤០នាក់ ក្នុងកម្មវិធី២៤គម្រោងជូនដល់បងប្អូនខ្មែរជាង៤០០នាក់, កម្មវិធីអប់រំកុមារ និងវ័យជំទង់១០០០នាក់, ជនវ័យកណ្តាល២៧០០នាក់, ជនវ័យចំណាស់ ៤០០នាក់ និងតាមរយៈការផ្សាយដំណឹងអប់រំដល់បងប្អូនជាង១២០០០នាក់ទៀតផង ។

-សមាគមខ្មែរនៅទ្វីបអាមេរិក (C.A.A) ប្រតិបត្តិការងារក្នុងកម្មវិធីធំៗចំនួន១៧គម្រោងដែលគាំទ្រថវិកាដោយរដ្ឋាភិបាលសហព័ន្ធរដ្ឋ, ស្រុកឬក្រុង និងមូលនិធិឯកជន ។ ដោយគម្រោងការងារក្រោមជំនួយថវិកានោះបានជំរុញឱ្យជីវិតមនុស្សជាង១៥០០នាក់ ដែលបានទទួលសេវាកម្មផ្ទាល់ពីសមាគម និងជាង៣០០០នាក់ ដែលចាប់យកកម្មវិធីអប់រំជារៀងរាល់ឆ្នាំពីសមាគមខ្មែរមួយនេះ ។

-ទោះបីសមាគមនេះបានលាតត្រដាងពីសកម្មភាពខ្លួន ដើម្បីសហគមន៍ខ្មែរ និងសង្គមសាសន៍ដទៃទៀតពីអំពើខ្លួន ក្នុងការអភិវឌ្ឍន៍ក៏ដោយ ។ ក៏ពាក្យរិះគន់បាន

(តទៅទំព័រទី៣០)

## ព្រឹត្តការណ៍ថ្ងៃ៧មករា...

ករណីខ្ញុំពិតមែនតែខ្ញុំមេបញ្ជាការកងទ័ព នៅពេលដែលខ្ញុំហៅតេឡេហ្វូនទៅគេហៅដាច់ៗ ខ្ញុំទាក់ទងឥតបានទាហានគេចូលដល់ព្រៃបណ្តោយ ។ គេចាប់ខ្ញុំនៅគេហដ្ឋានរបស់ខ្ញុំផ្ទាល់តែម្តងនោះឯង ខ្ញុំពេលនោះឃើញរថក្រោះព័ទ្ធជុំវិញផ្ទះរបស់ខ្ញុំ ហើយខ្ញុំឃើញឡានកំម៉ងកាគេចូលមកពេលនោះខ្ញុំទៅលេងសីពេលជិតយប់ ហើយម៉ោង៥កន្លះខ្ញុំចូលដល់ផ្ទះ ហើយក៏ឃើញថា កងទ័ពយៀកណាមគេចូលព្រៃបៗឈរតាមរបងពេញជិតអស់រលីង ខ្ញុំហៅតេឡេហ្វូនទៅអគ្គសេនាធិការនៅក្រសួងការពារជាតិកំពុងហៅតេឡេហ្វូនអីចឹង ក៏ឃើញលោក សាយ ប៊ុនថង ឡើងមក លោក ហ៊ុន សែន ឡើងមកលោក សាយ ប៊ុនថង គាត់ថាបងឯងក្បត់ជាតិចាំស្តាប់សេចក្តីសម្រេចរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជាសុំដកតំណែងគ្រប់តំណែងពីបងឯង ហើយបងឯងត្រូវជាប់គុកនៅហាណូយ ។

ពេលហ្នឹងគេរឹតខ្នោះទាំងជើងទាំងដៃ ហើយគេយកក្រណាត់ខ្មៅចងរុំមុខបោះខ្ញុំទៅក្នុងឡានកំម៉ងការ គេតាបជាប់យកទៅដាក់ឃុំនៅព្រលានយន្តហោះពោធិចិនតុងប្រហែលមួយយប់ម៉ោង ៩:៤៥ នាទី ថ្ងៃទី ៣ ខែធ្នូ ១៩៨១ គេបញ្ជូនខ្ញុំទៅហាណូយដាក់ក្នុងកន្លែងងងឹតបណ្តោយ ។

### ៧- តាម៉ុក បាននិយាយថា :

យួនលេបកម្ពុជានេះ យួនយកទឹកដីកម្ពុជានេះ មិនមែនរឿងធម្មតាទេ ហើយក៏មិនមែនជំនាន់តែអ៊ុងដែរ គឺរឿងនេះវាជាយុទ្ធសាស្ត្រថ្មីរបស់យួន សង្គ្រាមយួននេះគឺជាសង្គ្រាមមនុស្សវាអត់ប្រើអាវុធទេ មកយកកម្ពុជាមកលេបទឹកដីកម្ពុជា គឺវាប្រើមនុស្សបញ្ចូលមនុស្ស ។ កម្ពុជាបច្ចុប្បន្នគឺជាកម្ពុជាយួន បើយួនវាពេញទឹកពេញដីវាណែនតាន់តាប់អីចឹងអស់ទៅហើយៗ យើងទៅដោះស្រាយដោយឡែកៗម្នាក់ៗយើងទៅមិនរួចទេ ។

### ៨- លោក ខៀវ សំផន និយាយថា :

អ្នកដែលបំរើយួនឈ្លានពាននោះ បើកដៃអោយយួនចូលមកសម្លាប់ប្រជាជនកម្ពុជាតាំងពីផែនការក៥ តាំងពីស្ទើទៅគេហៅថាស្ទី ថាក្បត់ជាតិគ្រាន់តែលើកយកបញ្ហាខ្លះៗ ដើម្បីកំណត់ភាពពិតនៃបញ្ហាកុំអោយបន្ទែបន្ទំភាពពិតបញ្ហា ឥឡូវចាំបាច់បញ្ជាក់អោយច្បាស់ដូច្នេះ ។

ខ្ញុំគ្មានសិទ្ធិនិយាយពីប្រជាជនកម្ពុជាទេ គ្មានអ្វីអោយមកភន់ច្រឡំស្រពិចស្រពិលបានទេ ។

បច្ចុប្បន្នរដ្ឋាភិបាលលោក ហ៊ុន សែន កំពុងតែបានធ្វើការជាមួយអង្គការសហប្រជាជាតិពីបញ្ហាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលរហូតមកដល់សព្វថ្ងៃមានអតីតអនុលេខាបក្ស នួន ជា ឧបនាយករដ្ឋមន្ត្រីខ្មែរ ក្រហម អៀង សារី និងភរិយា អៀង ធីរិទ្ធ អតីតរដ្ឋ មន្ត្រីសង្គមកិច្ចកម្ពុជាប្រជាធិបតេយ្យលោកអតីតប្រមុខរដ្ឋខ្មែរក្រហម ខៀវ សំផន និងអតីតមេគុកទួល ស្លែង កាំង ហ្គិចអ៊ាវ ហៅឌុចត្រូវបានចាប់ខ្លួនដាក់ក្នុងមន្ទីរឃុំឃាំងដើម្បីឱ្យតុលាការកូនកាត់មួយនេះធ្វើការកាត់ទោស ។ ប៉ុល ពត ដែលនៅក្នុងសៀវភៅបោះពុម្ពផ្សាយទី២របស់ ខៀវ សំផន ថា ជាវីរៈបុរសស្នេហាជាតិនេះបានស្លាប់បាត់បង់ជីវិត កាលពីដើមឆ្នាំ១៩៩៨ និង តាម៉ុក អគ្គមេបញ្ជាការខ្មែរក្រហម ក៏បានស្លាប់ទៅបាត់កាលពីដើមឆ្នាំ ២០០៧នេះ ហើយរដ្ឋមន្ត្រីក្រសួងការពារជាតិខ្មែរក្រហម សុន សេន ក៏ត្រូវបាន ប៉ុល ពតសំលាប់ទាំងគ្រួសារទៅដែរ តាំងពីឆ្នាំ១៩៩៦ ដែលជាការបន្តព្រួយបារម្ភពីការបាត់បង់ភស្តុតាង ប្រសិនពួកអ្នកដែលត្រូវឃុំខ្លួនទាំងនេះ បន្តស្លាប់ជាបន្តបន្ទាប់ទៅទៀតនោះ និងប្រសិនមានការយឺតយ៉ាវរបស់តុលាការទៀតផង ៕

**រាយការណ៍បន្ថែមដោយៈមាជសុវណ្ណារ៉ា**



LENG
BEAUTY SALON
ហាងកាត់សក់-សំអាងការ
2224 E. ANAHEIM STREET • LONG BEACH, CA 90804
(562) 434-9621
មានជាងចំណានៗដែលមានការពិសោធន៍ជាច្រើនឆ្នាំជាមួយជំនាញកាត់សក់, អ៊ុតសក់ សម្រាប់មនុស្សគ្រប់វ័យ បុរស-ស្ត្រី ។
ហាងយើងខ្ញុំក៏មានទទួលតែងការក្នុងពិធីរៀបអាពាហ៍ពិពាហ៍តាមម៉ូតស៊ីវិល័យទាន់សម័យនិយម់ឬបែបប្រពៃណីបូរាណ ។
-ទទួលសាក់ចិញ្ចើម និងតួរភ្នែក
សូមអញ្ជើញ ដោយមេត្រីភាព!
ហាងយើងខ្ញុំត្រូវការរកជាងលាបក្រចកម្នាក់ និងរកជាងអ៊ុតសក់ម្នាក់ !








ចាប់ផ្តើមហើយ!

Sopheary Band

For info.
(562) 400-7678
Fri. & Sun. $5
Expt.Sat.$10



New Band in Khmer Town

ROSMANNEE RESTAURANT 1223 E. Anaheim St., Long Beach, CA 90813
Started: 11-30-07 to 12-31-07 8:00 pm to 1:00 pm
Except. Sun. 8:00 pm - 12:00pm

Proper attire & Must be 21

# ខ្មែរប៉ុស្តិ៍ និងអ្នកគាំទ្រឱ្យផ្សាយ......

នៃឆ្នាំចាស់ដោយផ្លាស់ជំនួសមកវិញនៅឆ្នាំថ្មី ជួបតែសុខភាពល្អប្រពៃមានសុភមង្គលក្នុងគ្រួសារ និងជួបប្រទះនៅលាភសក្ការៈហូរចូលតាមបំណងប្រាថ្នា។

-ខ្មែរប៉ុស្តិ៍សូមអគុណចំពោះបងប្អូនជាអ្នកគាំទ្រកាសែតខ្មែរមួយនេះ មានដង្ហើមជីវិតរស់រានមកដល់ថ្ងៃនេះ ក៏ព្រោះតែថវិការបស់លោកអ្នក ដែលជាដើមទុនក្នុងការបោះពុម្ពផ្សាយជាបន្តបន្ទាប់នោះ ដើម្បីចូលរួមចំណែកបំរើដល់សហគមន៍ខ្មែរនានាក្នុងសហរដ្ឋអាមេរិក ។

-ការគាំទ្រពីបងប្អូន គឺជាកំលាំងចិត្តដ៏រឹងមាំមួយជំរុញឱ្យកាសែតខ្មែរប៉ុស្តិ៍ត្រូវតែប្រឹងប្រែងឱ្យអស់ពីសមត្ថភាពការងារក្នុងនាមជាក្រុមអ្នកសារព័ត៌មានឯករាជ្យ ដោយឈរលើគោលការណ៍ក្រមសីលធម៌វិជ្ជាជីវៈអ្នកកាសែត (Check, Balance and Fair) ដើម្បីនាំមកនូវដំណឹងពិតៗពីអ្វីដែលកើតមាននៅជុំវិញសហគមន៍អស់លោកអ្នក ឬពីមាតុភូមិកម្ពុជានៃយើង សំរាប់ជាចំណីចក្ខុអារម្មណ៍របស់អស់លោកអ្នកស្តីពីនយោបាយ សេដ្ឋកិច្ច សង្គម សន្តិសុខសាធារណៈ វប្បធម៌ សាសនា អក្សរសាស្ត្រ នាទីប្រវត្តិសាស្ត្រនាអតីតកាល និងបច្ចុប្បន្នតាមការឆ្លុះបញ្ចាំងក្នុងទំព័រកាសែតខ្មែរប៉ុស្តិ៍។

-ខ្មែរប៉ុស្តិ៍ ដែលមានសិទ្ធិត្រឹមតែជាអ្នកនាំពាក្យផ្លូវកណ្តាល និងការបរិយាយនូវអ្វីដែលជាការពិត (តថភាព) និងសត្យានុម័តដែលល្អ ឬអាក្រក់ ពីទង្វើរបស់មនុស្ស ឬសង្គមទៅតាមភស្តុតាងជាសំអាងដោយមិនឈរលើអគតិទាំង៤ ដោយសរសេរជាពត៌មាន, និពន្ធ ឬការធ្វើអត្ថាធិប្បាយ ព្រោះតែការស្អប់ (ទោសាគតិ) ការស្រលាញ់ (ឆន្ទាគតិ) ការខ្លាច (ភយាគតិ) និងការលង់ (មោហាគតិ) នោះទេ។ ដូច្នេះអគតិទាំង៤នេះ ខ្មែរប៉ុស្តិ៍មិនអាចដើរតាមគន្លងណាមួយបានឡើយ ដើម្បីជៀសវាងការនាំមកនូវភាពវឹកវរ, វិទ្ធស្សនា និងការបំបែកបំបាក់សហគមន៍ និងធ្វើឱ្យមនុស្សឃ្លាតពីការស្រលាញ់ ឬពីមិត្តភាពគ្នានោះ។

-ខ្មែរប៉ុស្តិ៍សង្ឃឹមថា លោកអ្នកនឹងបន្តការគាំទ្រកាសែតខ្មែរមួយនេះ ដើម្បីសង្គមលោកអ្នក ឬជាកាសែតរបស់លោកអ្នក ទៅតាមការវាយតំលៃពីលោកអ្នកចំពោះក្រុមអ្នកយកព័ត៌មានយើង ដោយជួយផ្តល់នូវគំនិតយោបល់ទស្សនៈមតិ ឬការរិះគន់ ដើម្បីស្ថបនាក្នុងការឆ្ពោះទៅរកចំណុចមួយរួមចំណែកអភិវឌ្ឍន៍សហគមន៍យើងទាំងអស់គ្នា ។

-ជាទិដ្ឋភាពរួមក្នុងយុទ្ធសាស្ត្រព្រួញមួយបាញ់បានសត្វពីរលោកអ្នកដែលបានផ្សាយពាណិជ្ជកម្មជាមួយខ្មែរប៉ុស្តិ៍ គឺលោកអ្នកនឹងបានចំរើនក្នុងកិច្ចការងាររបស់លោកអ្នកផង ហើយលោកអ្នកក៏បានចូលរួមការកសាងសង្គមខ្មែរ ដោយការឆ្លុះបញ្ចាំងតាមរយៈកាសែតខ្មែរប៉ុស្តិ៍ទៀតផង។/


SAMS BODY & PAINT (562) 489-2877 MECHANICAL

ហាងខ្មែរធ្វើតួ និងបាញ់ថ្នាំរថយន្ត
SAM'S AUTO BODY

CUSTOM COLLISION REPAIRS
COMPLETE AUTO PAINTING
RESTORATION INSURANCE WORK
FLAT BED TOWING AVAILABLE





BORIN
TEL: 562-489-2877
FAX: 562-489-0022
CEL: 562-577-8259
EXPERT FRAME & BODY WORK
1427 Long Beach Blvd., Unit A, Long Beach, CA 90813

ហាងយើងខ្ញុំ និងជូលរថយន្ត អោយជិះដោយមិនគិតថ្លៃ បើលោកអ្នកយករថយន្តមកធ្វើនៅកន្លែងយើងខ្ញុំ




## អាណិតស្រុកណាស់..

នាយករដ្ឋមន្ត្រីជប៉ុនជាដើម គេសុខចិត្តចុះចេញពីតំណែងខ្លួនឯង ដោយសារគេមើលឃើញ និងឮនូវហេតុការណ៍អ្វីៗដែលនៅជុំវិញខ្លួនគេ ដែលគេយល់ថាជាកំហុសរបស់ខ្លួន ហើយខ្លួនពុំត្រូវអាចក្រាញនៅក្នុងអំណាចទុកឱ្យបញ្ហាធំៗនោះរីករាលដាលខ្លាំងឡើងតទៅមុខទៀតយូរបានទេ គឺត្រូវតែស្វែងរកវីរៈជនមួយថ្មីទៀត មកជំនួសដោយប្រើវិធីលទ្ធិប្រជាធិបតេយ្យបោះឆ្នោតជ្រើសរើសយកមកកាន់តំណែងនាយករដ្ឋមន្ត្រីអោយដោះស្រាយកែប្រែបញ្ហាទាំងនោះឱ្យល្អប្រសើរ និងមានស្ថេរភាពឡើងវិញ ។

នេះបានហៅថា នាយករដ្ឋមន្ត្រីមានគតិបណ្ឌិត និងឧត្តមគតិយុត្តិធម៌ត្រឹមត្រូវពិតប្រាកដមែន ហើយត្រូវតែគោរព និងកោតសរសើរ។

ផ្ទុយទៅវិញ មាននាយករដ្ឋមន្ត្រីប្រទេសខ្លះ ត្រឡប់ទៅជាក្រាញនៅក្នុងអំណាច ដោយយល់ថា មានតែខ្លួនឯងម្នាក់គត់ ដែលមានប្រាជ្ញាវៀងវៃឈ្លៀវឆ្លាត និងមានគតិបណ្ឌិត រហូតទុកខ្លួនឯងស្មើនឹងស្តេចផែនដីដែលមានបុណ្យសិទ្ធិគ្រប់គ្រងប្រទេសតពូជពង្សវង្សត្រកូលបានទៅវិញទៀតផង ។ តួយ៉ាងដូចជាអតីតនាយករដ្ឋមន្ត្រីប្រទេស ថៃ ប្រទេស ភូមា ជាដើម។

ក្នុងរឿងនេះ អតីតនាយករដ្ឋមន្ត្រី ថៃ ឈ្មោះ តាក់ស៊ីនជិនណាវ៉ាត់ ត្រូវបានកងទ័ពជាតិថៃធ្វើរដ្ឋប្រហារទំលាក់ចេញពីអំណាច ក្រោយពីមានប្រជាពលរដ្ឋថៃស្នេហាជាតិបានបណ្តេញអោយចុះចេញពីអំណាចតែពុំព្រមចុះ។

នៅប្រទេស ភូមា ក៏មានការប្រកាសពីអន្តរជាតិដើម្បីដាក់ទណ្ឌកម្មគាបសង្កត់ផ្នែកសេដ្ឋកិច្ចដែរ ដោយសារតែមេដឹកនាំប្រើអំណាចផ្តាច់ការ។

-តើនៅក្នុងប្រទេសខ្មែរ កំពុងស្ថិតនៅក្នុងស្ថានភាពដូចម្តេចដែរសព្វថ្ងៃនេះ ?

-តើនាយករដ្ឋមន្ត្រីខ្មែរ និងគណបក្សនយោបាយដ៏មហិមារបស់លោកមានគម្រោងកាន់អំណាចទៅមុខទៀតជារៀងរហូត ឬដូចម្តេច ?

បើតាមសំដីប្រកាសថ្លែងនៅក្នុងពេលប្រជុំមហាសន្និបាតប្រទេសអាស៊ាននៅពេលថ្មីៗនេះ ហាក់បីដូចជាសម្តេចអគ្គមហាសេនាបតីតេជោពុំមានបំណងចុះចេញពីតំណែងទេ ដោយសម្តេចបានអះអាងថា លោកបានកាន់អំណាចជិត៣០ឆ្នាំហើយ លោកជាប្រមុខរាជរដ្ឋាភិបាលខ្មែរតែមួយគត់ក្នុងប្រវត្តិសាស្ត្រខ្មែរ ដែលមានគតិបណ្ឌិត និងគតិយុត្តិធម៌ត្រូវតែបានកាន់អំណាចដ៏យូរលង់ ដូចជាមានមេដឹកនាំប្រទេសជាច្រើនបានថ្លែងកោតសរសើរ និងគោរពកោតខ្លាចដល់សម្តេចអគ្គមហាសេនាបតីតេជោដែរ។

ដូច្នេះប្រទេសកម្ពុជានាសម័យនេះ ត្រូវតែមាននាយករដ្ឋមន្ត្រីមួយរូបកាន់អំណាចជារៀងរហូតតទៅ ពីព្រោះនៅក្នុងច្បាប់កំពូលរដ្ឋធម្មនុញ្ញពុំមានមាត្រាណាចែងអំពីការតម្រូវកំណត់ចំនួនឆ្នាំ ឬអាណត្តិនៃប្រមុខរដ្ឋាភិបាលឡើយ ហើយនឹងពុំមានចែងពីលក្ខណៈឯករាជ្យ និងអព្យាក្រិត្យនៃគណកម្មាធិការកណ្តាលនៃការបោះឆ្នោតជ្រើសរើសតែងតាំងសភា និងប្រមុខរដ្ឋាភិបាលផងដែរ។/


ឱសថស្ថានខ្មែរថ្ងៃនេះ
Today Pharmacy
2200 E. Anaheim St.#C Long Bach, CA 90804
Tel: (562) 438-2031 • Fax: (562) 438-2031
(2 Blocks East of Cherry Ave.)
Fast and Friendly Service
- Today Pharmacy គឺជាឱសថស្ថានបំរើការចែកចាយថ្នាំតាមវេជ្ជបញ្ជា ។
- ទទួលយកនៅ Medicare & Medical និង Insurance ។
- ដឹកជញ្ជូនថ្នាំផ្តល់ជូនឲ្យដល់គេហដ្ឋានដោយមិនគិតពីកំរៃផងដែរ ។
• FREE DELIVERY TODAY:
ថ្ងៃល្អរបស់លោកអ្នក សូមស្វាគមន៍!

# ផ្ដល់សំណាងឱ្យកុមាររើសសម្រាមខ្មែរ

●●●ពីស្ថានសួគ៌នៃសំណល់មានចាស់មានថ្មីនៃសហរដ្ឋអាមេរិក មនុស្សម្នាប្រមាណ៥០០នាក់នៅហ្វីឡាដែលហ្វីយ៉ានាំគ្នាទស្សនាខ្សែភាពយន្តឯកសារមួយ ដែលនិយាយអំពីកុមាររើសសំណល់តិចតួចនៃសំរាមភ្នំពេញដើម្បីចិញ្ចឹមជីវិត ។

ខ្សែភាពយន្តនោះបានត្រូវបញ្ចាំងនារាត្រីថ្ងៃសៅរ៍ ទី៨ ខែធ្នូកន្លងទៅនេះ ដើម្បីទាក់ទាញសប្បុរសជនទាំងខ្មែរ និងបរទេសឱ្យបោះដៃទៅជួយស្រោចស្រង់ជីវិតកុមារខ្មែរ ដែលមិនទាន់ស្លាប់ដោយសារជម្ងឺ តែកំពុងស្លាប់ដោយសារអត់អាហារបរិភោគរាល់ថ្ងៃ ។ សំរាមដែលទស្សនិកជនបានឃើញ ហើយមានជំនឿថា ក្លិនស្អុយអាចជះប្រាស់ខ្យល់បាន បានក្លាយជាប្រភពនៃម្ហូបអាហារសំរាប់រស់ ម្យ៉ាងស្ទើរតែមិនគួរជឿ ប្រសិនជាគេគ្មានភស្តុតាងមកបង្ហាញទេនោះ។ លោក ជន វេលី ជាប្រធានមូលនិធិកុមារខ្មែរមានអាស័យដ្ឋាននៅឡូសអង់ជើឡេស រួមគ្នានឹងគណកម្មាធិការខ្មែរក្រុងហ្វីឡាដែលហ្វីយ៉ាមានគ្រួសារ សេរីម៉ៅ គ្រួសារ បូណា- វ៉ានស្តាញ និងមិត្តភក្តិជាច្រើនទៀត បាននាំគ្នាលើកបញ្ហានៃភាពអាសន្ននេះមកឱ្យសហគមន៍ដែលមានកំណើតជាខ្មែរឱ្យជួយគាំទ្រដល់ជីវភាពគ្រួសារខ្មែរទាំងនោះ ។

ហ្វីឡាដែលហ្វីយ៉ាជាថ្មីម្តងទៀត បានសំដែងការអាណិតអាសូរដល់ប្រជាពលរដ្ឋដែលមានកំណើតដូចខ្លួនតែវាសនាតូចទាប ដោយបរិចាកថវិកាបានចំនួន បីម៉ឺនដុល្លា នារាត្រីថ្ងៃសៅរ៍ ទី៨នោះ ផ្ញើទៅជួយអ្នកទាំងនោះ។ ស្នាដៃនេះបានធ្វើឱ្យអ្នកនៅហ្វីឡាដែលហ្វីយ៉ា ក្លាយជាសហគមន៍ដ៏មានចិត្តសប្បុរសជាងគេ បើទោះណាជាខ្លួនជាសគមន៍ក្រីក្រជាងគេក៏ដោយ ។/








1310B Stanley Ave
Long Beach, CA 90804 (562) 433-8090,(562) 433-8093


## RELIVសុខភាពល្អ

**NEWS reliv UPDATE**




ផលិតផលសុខភាពធ្វើពីធម្មជាតិសុទ្ធសាធ នៅសហរដ្ឋអាមេរិកឈ្មោះ RELIV នេះ អាចជួយដល់ភាពជរាទ្រុឌទ្រោមរបស់មនុស្សចាសខ្ញុំជា ពិសេសជួយដល់មនុស្សធ្វើការច្រើន នាំឱ្យចាស់មុនអាយុជួយបន្ថយការឈឺចុកចាប់នៅសន្លាក់ដៃជើង ឬរោគស្ត្រី និងបុរសមួយចំនួនគេហៅថា RELIV នេះថាជា "អាហារសុខភាពល្អ" ស្រួលពិសារដែលលោកអ្នកគួរប្រើដូចគ្នានឹងពិសារទឹកក្រូច នារាល់ព្រឹកមុននឹងចេញទៅក្រៅធ្វើការម្តង១ ដើម្បីលើកកម្លាំងបំពេញការងារដោយងាយស្រួលអ្នកប្រើប្រាស់ RELIV នៅជុំវិញ ស.រ.អា នេះ គ្រប់សាសន៍ សញ្ជាតិ បានថ្លែងអំណរគុណដល់ RELIV អាហារ VITAMIN ដែលបានជួយសំរាលការឈឺចុកចាប់ជួយបន្ថយការប្រើថ្នានានាច្រើនមុខ ដោយសារតែការផ្សំផលិតផលនេះ ដើម្បីទៅបំពេញដល់ការខ្វះខាតជីវជាតិក្នុងចំណីអាហារដែលលោកអ្នកពិសាររាល់ថ្ងៃ ។ មានជីវជាតិចិញ្ចឹមសរីរាង្គឡើងវិញ ។ សរីរាង្គយើងក៏ដើរពេញកម្លាំងឡើងវិញ ។ ការឈឺថ្កាត់ក៏ចុះថយទៅបាត់ស្មារតី នឹងកម្លាំងអន់ថយ ក៏កើនឡើងយ៉ាងឆាប់រហ័ស ។

RELIV ជាផលិតផលអាមេរិក តម្លៃថោកមានប្រសិទ្ធិភាពដែលលោកអ្នករកជាវនៅទូរស័ព្ទលេខ..... ហើយ ប្រាប់លេខ Sponsor ។

**ហើយបើលោកអ្នកចង់លក់ RELIV នេះ**
**សូមទូរស័ព្ទសួររកធីម (ធី ) លេខ (២១៥) ៧៧៦ ៤១៧៤**





K2J cafe (562) 498-0383 www.k2jcafe.com
3753 E. Anaheim St., Long Beach, CA 90804

**ដំណឹងលក់ហាង**

យើងខ្ញុំត្រូវការលក់ហាង Donutបើលោកអ្នកចង់ទិញហាងយើងខ្ញុំ សូមទាក់ទងមកលេខទូរស័ព្ទ

**(626) 318-7665**

ហាង Donutយើងខ្ញុំស្ថិតនៅទីប្រជុំជនតំបន់រស់នៅល្អធានាសន្តិសុខ

**ដំណឹងលក់ហាង**

-ហាងខ្មែរ LIQUOR នៅរដ្ឋ TEXASត្រូវការលក់ តំបន់មានសុវត្ថិភាព,អំណោយផលផលល្អសំរាប់ធ្វើជំនួញរបស់លោកអ្នក ដោយមិនខុសបំណងឡើយ ។

-សូមកុំឱ្យឱកាសល្អកន្លងផុត .ទាក់ទងជាមួយខ្ញុំឈ្មោះ RICK នូវទូរស័ព្ទ :

**(៩៤០) ៧៨១-៥៩៦៣ ឬ (៩៤០) ៦៨៧-៩៩៨៨**

▶Excellent Location, Includes Land and a new automatic car wash
▶Corner lot, good visibility ▶cornerete /Asphalt Parking ▶Additional building can be Added
▶Check Cashing,Western Union, Lottery ▶Liquor stor Gross = $ 650 k
▶Liquor stor Gross = $ 650 k ▶Automatic car wash = $ 30 k
▶Check Cashing and western Union = $ 30 k ▶Offered at $ 690,000 + Tnventories


ASIAN PACIFIC INTL TRAVEL
ក្រុមហ៊ុនលក់សំបុត្រយន្តហោះ
មានលក់សំបុត្រគ្រប់ក្រុមហ៊ុនទៅ
កម្ពុជាដូចជា:
-Eva Airways
-China Airlines
-Singapore Airlines
-Thai Airways
-Malaysia Airlines
-Cathay Pacific
-Korea Airlines
-Asiana Airlines
*មានលក់សំបុត្រទៅប្រទេសផ្សេងៗទៀត ដូចជា: អឺរ៉ុប
*មានលក់សំបុត្រក្នុងប្រទេស USA
*មានលក់សំបុត្រយន្តហោះពីភ្នំពេញមក USA
កន្លែងនាងខ្ញុំមានប្រថាប់ត្រា
Notary Public Phone Card
Buy 4 get 1 free
$ 965 Tax included
ទទួលរៀបចំធ្វើ
Reentry , Permit , Urgent ,
ធានាប្តីប្រពន្ធ,គូដណ្តឹង,ក្រុមគ្រួសារ
សូមលោកអ្នកអញ្ជើញមកដោយមេត្រី
Prepaid - Phone Cards
Toll Free 1-800- 359 -6698
CAL -STATE
Realty & Leading
Real Estate *Home Loans
*Residential * Commercial
You will get the best deal
Magaret (LiLy) Chung
Realtor
Sell your home at 3,5%
Buy your home at 1 % Rebate
ធ្វើការដោយស្មោះត្រង់និងយកចិត្តទុកដាក់ជានិច្ច
1065 E. Anaheim Street.
Long Beach CA 90813
Tel: (562) 599 - 5464
Fax : (562) 599-5604
Tony´s Cell : (562) 537-3546
LiLy´s Ceell : (562) 682-6588
4510 E. Pacific Coast Hwy,.
Ste.540 Long Beach, California90804
Tel: (562) 599-5464
Cell: (562) 682-6588
Fax: (562) 599-5604
Email : margaretchung@charter.net




# ផ្ញើប្រាក់ទៅកាន់ខេត្តណាមួយនៅកម្ពុជា តាមរយៈ Western Union

## ជាមួយថ្លៃ* សេវាកម្មផ្ញើប្រាក់ទាប $11.99 ដុល្លារ

សម្រាប់ការផ្ញើប្រាក់ទៅកាន់ខេត្តក្រុង** ដែលបានជ្រើសរើសក្នុងចំនួនតិចជាង 500 ដុល្លារ

## ជាទូទៅប្រាក់អាចទទួលបានតែប៉ុន្មាននាទី*** ប៉ុណ្ណោះ

- ✓ ថ្លៃ* សេវាកម្មផ្ញើប្រាក់មិនមានការប្រែប្រួលទៅតាមទីកន្លែងរបស់ភ្នាក់ងារទទួលប្រាក់ឡើយ
- ✓ មានភ្នាក់ងារផ្ទេរប្រាក់ជាង 100 កន្លែងនៅ 24 ខេត្តក្រុងទូទាំងប្រទេសកម្ពុជា
- ✓ មិនចាំបាច់មានគណនីនៅធនាគារទាំងអ្នកផ្ញើ និងអ្នកទទួល
- ✓ មិនមានការគិតថ្លៃសេវាកម្មផ្ទេរប្រាក់ពីអ្នកទទួលឡើយ

**WESTERN UNION**®

សេវាកម្មផ្ទេរប្រាក់ទូទាំងពិភពលោក រហ័សទាន់ចិត្ត និងគួរឲ្យទុកចិត្ត

**សូមទាក់ទងទូរស័ព្ទ 1-800-325-6000**

ភ្នាក់ងារផ្ទេរប្រាក់នៅកម្ពុជាដែលទទួលបានការអនុញ្ញាតពី Western Union: CAB BANK SBC Bank

| | | | | |
|---|---|---|---|---|
| **NHA THUOC THIEN NHIEN**<br>1299 E. ANAHEIM ST<br>LONG BEACH, CA 90813<br>TEL: 562-218-2328 | **MONEY MART #0772**<br>1001 E. PACIFIC COAST HWY<br>LONG BEACH, CA 90806<br>TEL: 562-599-0991 | **MONEY MART #0767**<br>2375 LONG BEACH BLVD<br>LONG BEACH, CA 90806<br>TEL: 562-427-0253 | **CONTINENTAL CURRENCY #704**<br>3106 SAN GABRIEL BLVD<br>ROSEMEAD, CA 91770<br>TEL: 626-280-0380 | **TOPANGA CHECK CASHING**<br>7239 TOPANGA CANYON BLVD<br>CANOGA PARK, CA 91303<br>TEL: 818-594-0057 |
| **CONTINENTAL CURRENCY #408**<br>1301 LONG BEACH BLVD<br>LONG BEACH, CA 90813<br>TEL: 562-599-1550 | **ANTOJITOS LATINOS LIQUOR**<br>25381 ALICIA PKWY STE N<br>LAGUNA HILLS, CA 92653<br>TEL: 949-215-9708 | **NADERS MARKET**<br>25227 REDLANDS BLVD # I<br>LOMA LINDA, CA 92354<br>TEL: 909-796-1660 | **CONTINENTAL CURRENCY #413**<br>237 LONG BEACH BLVD<br>LONG BEACH, CA 90802<br>TEL: 562-432-5883 | **SIAM MARKET**<br>2505 E. ANAHEIM ST<br>LONG BEACH, CA 90802<br>TEL: 562-607-8970 |

*សម្រាប់ការផ្ទេរប្រាក់ដុល្លារអាមេរិចប៉ុណ្ណោះ។

**ថ្លៃសេវាកម្មផ្ញើប្រាក់នេះមានសុពលភាពចាប់ពីថ្ងៃទី 22 ខែ តុលា ឆ្នាំ 2007 នេះនៅតាមបណ្តាភ្នាក់ងារនានាដែលបានចូលរួមក្នុងកម្មវិធីរបស់ខ្លួននៅតំបន់ប្រជុំជន Los Angeles និង Philadelphia ។ Western Union សូមរក្សាសិទ្ធិក្នុងការកែប្រែដោយមិនចាំបាច់ជូនដំណឹងជាមុន។ ថ្លៃសេវាកម្មផ្ញើប្រាក់អាចត្រូវបានគិតច្រើនជាងនេះសម្រាប់ការផ្ញើប្រាក់តាមរយៈទូរស័ព្ទ និង តាមរយៈគេហទំព័រ www.westernunion.com ។

***រយៈពេលនៃការទទួលប្រាក់អាស្រ័យទៅលើកត្តាមួយចំនួននៃសេវាកម្មរួមទាំងម៉ោងធ្វើការ និងទីតាំងរបស់ទីភ្នាក់ងារផ្ទេរប្រាក់ព្រមទាំងភាពខុសគ្នារវាងម៉ោងនៅក្នុងតំបន់នីមួយៗផងដែរ។ ពិនិត្យមើលកត្តាកំណត់ និងល័ក្ខខ័ណ្ឌនានានៅក្នុងបែបបទ "ផ្ញើប្រាក់"។

©2007 Western Union Holdings, Inc. All Rights Reserved.




ក្រុមហ៊ុន CATHAY PACIFIC AIRWAYS បានផ្តើមការហោះហើរបំរើអតិថិជន ចាប់ពីខែ ធ្នូ ឆ្នាំ ២០០៧ នេះទៅហើយ នូវប្រភេទយន្តហោះ BOEING ថ្មីដ៏ធំបំផុតដែលរចនាតុបតែងឡើងយ៉ាងល្អប្រណិតក្នុងបច្ចេកទេសខ្ពស់ និងជាសុខភាពល្អ កៅអីធំទូលាយងាយស្រួលអង្គុយ និងចេញចូល ទូរទស្សន៍ផ្ទាល់ខ្លួន មានទំហំធំរហូតដល់៩អ៊ីង សំរាប់ថ្នាក់ជិះផ្នែក ECONOMY ។

ក្រុមហ៊ុន CATHAY PACIFIC ហោះហើរពាជើងក្នុងមួយថ្ងៃពី LOS ANGELES ទៅ HONG KONG ។ ពី HONG KONG ទៅ PHNOM PENH រៀងរាល់ថ្ងៃ (រយះពេលហោះហើរតែ ២:៣០ នាទី តែប៉ុណ្ណោះ ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានលើយន្តហោះមានជាភាសាខ្មែរផងដែរ ។

# វិមានមាស ភោជនីយដ្ឋាន និង រង្គសាល

1360 E , Anaheim St., Long Beach, CA 90813

Tel: (562) 591-7300 Fax: (562) 591-7331

Mon., Wed., Thu, 10AM- 10PM
Fri, Sat, Sun, 9 AM -2 AM (LIVE ! BAND )
Tuesday (Closed)



សូមអញ្ជើញភ្លក្សរសជាតិម្ហូប ខ្មែរ ថៃ នៅភោជនីយដ្ឋាន **វិមានមាស** ដែលបានបើកទ្វារបំរើអស់លោកអ្នក ចាប់តាំងពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ នេះហើយ !!!




ចំណែកឯរង្គសាល **វិមានមាស** ក៏បានបើកទ្វារបំរើអស់លោកអ្នក រាំកំសាន្តជាមួយក្រុមតន្ត្រី **វិមានមាស** រៀងរាល់ចុងសប្តាហ៍ ចាប់ពីថ្ងៃ សុក្រ រហូតដល់ថ្ងៃ អាទិត្យ

ភោជនីយដ្ឋាន និង រង្គសាល វីមានមាស មាន ទទួលសំអាងការ ទទួលរៀបអាពាហ៍ពិពាហ៍ បុណ្យខួបកំណើត និង ពិធីជប់លៀងផ្សេងៗ...

---




# Quality Assured Collision Center

"We do what's right to ensure your vehicle gets back to pre - accident condition"

1427 long beach , Blvd , Suite B
Long Beach , California , 90813
T : 562 599 0766 , F : 562 599 6504
QACollison@yahoo.com



## " Mission Statement "

To Provide the highest quality of workmanship in reasonable time , while building a lifetime relationship with our customers

ធ្វើតួ និង បាញ់ថ្នាំឡាន
ជាមួយជាងជំនាញៗ មានបទពិសោធន៍ខ្ពស់
ធ្វើឱ្យលោកអ្នកមិនខកបំណងឡើយ !












## " Services Offered "

- Fast repairs with State-of-the-art equipment .
- Lifetime warranty on body and paint .
- Free estimates .
- Shuttle service .
- Free loaner vehicles , up 7 days .
- Free towing with vehicle repairs .
- I-CAR Free certified technicians .
- costomer Friendly staff .
- Waiting room with wireless internet .
- Computerized framer measurement , print put .
- Expert color mach .
- Auto mechanic on staff .
- 25 working boys .
- 65,000 square feet facility .
- We work with all insurance companies .

## STATE -OF-THE-ART Equipment

- 2 chief EZ line 3 post frame machine .
- Garmat downdraft beated spray booth .
- PPG paint mixing room .
- Robinair air condition system reclaim ,evacuate and recharge equipment .
- CCC pathways estimating software .



# វត្តវិបស្សនារាមការបោះឆ្នោតអាចបញ្ចប់ភាពវឹកវរ?

ដោយ : មាជ សុវណ្ណារ៉ា

-ទីបញ្ចប់នៃការវិវាទចោទប្រកាន់គ្នារវាងក្រុមពុទ្ធបរិស័ទ និងក្រុមគណៈកម្មការវត្ត ក្នុងសំដីតឹងសរសៃកដាក់គ្នាជាង៤ម៉ោង បានឈានដល់ការយោគយល់គ្នាទៅរកការព្រមព្រៀងរៀបចំឱ្យមានការបោះឆ្នោតជ្រើសរើសគណៈកម្មាការពុទ្ធិកសមាគមខ្មែរប្រចាំវត្តវិបស្សនារាមជាថ្មី គោរពទៅតាមលក្ខន្តិកៈច្បាប់របស់សមាគម Non Profit មួយនេះ។ ខណៈដែលគណៈកម្មការវត្តវិបស្សនារាមបច្ចុប្បន្នអាក់ខានមិនបានអនុវត្តទៅតាមច្បាប់អត់មានការបោះឆ្នោតជាង១១ឆ្នាំមកហើយនោះ ។ ការបោះឆ្នោតនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៨ ។

-យោងតាមមាត្រាទី៤នៃលក្ខន្តិកៈសមាគមខ្មែរវត្តវិបស្សនារាមបានចែងថា រៀងរាល់ឆ្នាំគណៈកម្មការចាស់ត្រូវធ្វើមហាសន្និបាត ដើម្បីធ្វើការបោះឆ្នោតជ្រើសគណៈកម្មការថ្មី ដើម្បីបន្តអាណត្តិពីខ្លួននៅចុងសប្តាហ៍ទី៤ ថ្ងៃទី២៧ ខែមករា ។

-គណៈកម្មការបោះឆ្នោតដែលមានលោក តាំ ស័ក្តិផាន, លី ឡេប និងអង់ តូនីតឹម បានបង្ហាញលក្ខន្តិកៈនៃការបោះឆ្នោតជ្រើសរើសគណៈកម្មការពុទ្ធិកសមាគមខ្មែរប្រចាំវត្តវិបស្សនារាម ដែលខ្មែរប៉ុស្តិ៍ទទួលបានតាមសារ E-mail មាន១៤ចំណុច ដែលជារបៀបរបបសំរាប់យកទៅអនុវត្តក្នុងការបោះឆ្នោត ។



ពុទ្ធបរិស័ទលើកដៃស្នើឱ្យមានការបោះឆ្នោត

-កាលពីថ្ងៃទី៩ធ្នូ មុនមួយថ្ងៃនៃថ្ងៃបុណ្យទិវាគោរពសិទ្ធិមនុស្សនៅវត្តវិបស្សនារាម ហៅវត្តអាយវ៉ាប់ក្នុងក្រុងខ្មែរ Long Beach ក្រុមគណៈកម្មការវត្ត និងក្រុមពុទ្ធបរិស័ទប្រមាណ១០០នាក់ ដែលមានព្រះសង្ឃចូលរួមជាព្រះគណៈអធិបតីផងនោះ ការជំនួបប្រជុំស៊ីពេលជាង៤ម៉ោង ក្នុងបរិយាកាសអាប់អួរដណ្តើមគ្នានិយាយដោយគ្មានសណ្តាប់ធ្នាប់តាមរបៀបវិរៈនៃកិច្ចការរដ្ឋបាលអ្វីឡើយ ។ ដែលក្រុមតំណាងឱ្យពុទ្ធបរិស័ទមានលោក សុទ្ធ ប៉ាលីន, សរ ស៊ីថាល់ បានចង់និយាយ ដោយចាប់ផ្តើមស្នើឱ្យមានការបោះឆ្នោតជ្រើសរើសគណៈកម្មការវត្តជាថ្មី ទៅតាមលក្ខន្តិកៈសមាគមពុទ្ធិកវត្តវិបស្សនារាម ដែលក្រុមគវ៉ាចោទប្រកាន់ថា ខុសច្បាប់ដឹកនាំជាង១១ឆ្នាំមកហើយ ដោយមិនគោរពគោលការណ៍ និងថាមានការចាយវាយលុយវត្តមិនត្រឹមត្រូវ ។ ចំណែកក្រុមគណៈកម្មការវត្តមានលោក ពៅ សាវន ប្រធានគណៈកម្មការ និងលោក ទិត ស៊ីផាន់ ជានាយកប្រតិបត្តិហាក់មិនចង់និយាយពីរឿងបោះឆ្នោតជ្រើសរើសគណៈកម្មការវត្តថ្មីអ្វីទេ ដោយពួកគេបានលើកពីរបៀបវិរៈពីបញ្ហាសាងសង់ព្រះវិហារ ។ ការខ្វែងសំណួរចោទសួរដាក់គ្នានោះហើយ

( តទៅទំព័រទី២១ )



លោក ពៅ សាវន ពន្យល់ពីឯកសារឱ្យអ្នកកាសែតខ្មែរប៉ុស្តិ៍ស្តាប់



អាចារ្យ វ៉េន ពៅ ឪពុកប្រធានគណកម្មការវត្ត ពៅ សាវន



ចៅសង្កាត់លេខ៦ Dee Andrews




# គណបក្សសិទ្ធិមនុស្សថ្កោលទោសការបំពានទៅលើព្រះសង្ឃ



អំពើហិង្សារបស់ប៉ូលិសចំពោះព្រះសង្ឃ





**ដោយ : មាជ សុវណ្ណារ៉ា**

-គណបក្សសិទ្ធមនុស្សកាលពីថ្ងៃ១៧កន្លងទៅនេះ បានចេញសេចក្តីថ្លែងការណ៍មួយថ្កោលទោសនៅអំពើហឹង្សាទាំងឡាយណាដែលបណ្តាលឱ្យមានការប៉ះពាល់ដល់រូបកាយព្រះសង្ឃឬគំរាមគំហែងណាមួយដែលធ្វើឱ្យព្រះសង្ឃមានការភ័យខ្លាច ។

-នៅសេចក្តីថ្លែងការមួយដែលខ្មែរប៉ុស្តិ៍ទទួលបានតាមសារ E mailនៅថ្ងៃទី១៧ធ្នូនោះគណបក្សសិទ្ធមនុស្សបានកត់សំគាល់ឃើញថាក្នុងរយៈលេខមួយចុងឆ្នាំក្រោយនេះ មានព្រះសង្ឃជាច្រើនអង្គបានរងនូវការធ្វើទុកបុកម្នេញ ពីអជ្ញាធរ ពីថ្នាក់នាំសង្ឃនិងពីជនមិនស្គាល់មុខដូចជាមានករណីសុគតភាពព្រះសង្ឃមួយអង្គនៅក្នុងវត្តទ្រនុំជ្រឹងក្នុងខេត្តកណ្តាលក្រោយពីបានចូលរួមធ្វើបាតុកឬកន្លងមក ក៏ដូចជាករណីព្រះតេជគុណ ទឹម សាខន និងព្រះសង្ឃផ្សេងទៀតនៅក្នុងឃុំបន្ទាយនាងស្រុកមង្គលបុរីខេត្តបន្ទាយមានជ័យត្រូវបានរតគេចខ្លួន ។

-ក្នុងសេចក្តីថ្លែងការរបស់គណបក្សរូបពន្លឺព្រះច័ន្ទក៏លើកពីករណីរបស់ព្រះសង្ឃជាង៤០អង្គបានរងនៅអំពីហឹង្សាវាយតប់គ្នាក្នុងការទាក់ទងក្នុងការនាំញត្តិទៅក្នុងស្ថានទូតវៀតណាមសូមឱ្យមានការដោះលែងព្រះតេជគុណ ទឹម សាខន និងព្រះសង្ឃ៥អង្គផ្សេងទៀតដែលត្រូវបានចាប់ដោយអជ្ញាធរវៀតណាព្រោះតែការទាមទារសិទ្ធកាន់កាប់ដីធ្លីកាលពីថ្ងៃទី១៧ធ្នូឆ្នាំ២០០៧នេះ ។ការប៉ះទង្គិចនោះបានបណ្តាលឱ្យព្រះសង្ឃ៦អង្គរងរបួសធ្ងន់និងព្រះសង្ឃជាច្រើនអង្គទៀតរងរបួសស្រាលនៅគ្រាដែលកងកំលាំងនគរបាលកម្ពុជាបានរុញច្រានព្រះសង្ឃខ្មែរក្រោមដែលកំពុងជាប់ពន្ធធនាគារ ។

-ក្រុមព្រះសង្ឃមានសង្ឃដីការថាក្រុម police បានរំលោភសិទ្ធព្រះសង្ឃដោយសំដីជេរ្មដាមរួចវាយព្រះសង្ឃពីដៃជាដំបូងដែលនាំឱ្យព្រះសង្ឃព្រួតគ្នាវាយព្រះសង្ឃវាយប៉ូលិសវិញ ។

-ក្រុមប៉ូលិសជាង១០០នាក់ប្រដាប់ទៅដោយដំបងឆក់របាំងការពារកាំភ្លើងវែងកាំភ្លើងខ្លីក្រវ៉ាត់ជុំវិញចង្កេះដោយគ្រាប់ផងនោះរុញច្រានព្រះសង្ឃទៅវិញទៅមករហូតមានការប្រគ្រាយប្រតប់គ្នា ។ ប៉ូលិសបានវាយព្រះសង្ឃនិងដំបងឆក់ពាស់ពេញថ្ពល់ រីឯព្រះ-សង្ឃក៏វាយតបតដោយគប់ policeនិងដបទឹកសុទ្ធផងដែរ ។ នេះបើតាមការអះអាងរបស់ក្រុមមន្ត្រីសិទ្ធិមនុស្សប្រាប់កាសែតខ្មែរប៉ុស្តិ៍ឱ្យដឹង ។

-លោកស្នងការប៉ូលិសក្រុងភ្នំពេញ ទូច ណារ៉ុថ បានបដិសេដប្រាប់អ្នកប្រមាញ់ពត៌មានថា កូនចៅរបស់លោកពុំបានវាយព្រះសង្ឃនោះទេ ដោយប៉ូលិសគ្រាន់តែការពារខ្លួនប៉ុណ្ណោះ ពេលដែលព្រះសង្ឃវាយមកលើក្រុមប៉ូលិសមុននោះ ។ ដោយលោកស្នងការប៉ូលិសក្រុងរូបនោះបានហៅទង្វើរបស់ព្រះសង្ឃជាទង្វើក្មេង

(តទៅទំព័រទី០៦)


Please, Ask for David
(562)599-1234

DJ Auto Body Parts Inc.

Quality Domestic & Foreign Auto Body Partrts

1130 Santa Fe Ave., Long Beach, CA 90813

Hoods • Fenders Grills • Bumpers
Radiator • A/C Condensers
All kind of Lights and More...

DJ SPECIALIZE IN:
-Spoilers -Mirrors
-Bed Liners -Side Step Bars
-Custom Lights
-Custom Grilles
-Custom Hoods
-Fan Assembly



DJ 20 % off with this coupon from Khmer Post






មន្ទីរពេទ្យគិត្យា ផេន
Khemara Family Medical Group
OPEN: Mon.-Fri. 9am - 5pm • Sat 9am - 1pm

1533 Alamitos Ave.,#B • Long Beach, CA 90813
Tel:(562) 218-5350 • Fax:(562) 218-1630

- ពិនិត្យជម្ងឺទូទៅ ជាពិសេសរោគមនុស្សចាស់ៗ
- ចាក់ថ្នាំការពារចូលរៀន
- ទៅមើលថែរក្សាអ្នកជម្ងឺដល់មន្ទីរពេទ្យ.និងទៅដល់ផ្ទះ

Pacific Hospital
L.B Memorial



សោភ័ណភាព

# ថែរក្សាបបូរមាត់ឱ្យស្រស់ស្អាត

**ពេលនេះ ដល់ពេលហើយ ដែលត្រូវចាប់អារម្មណ៍ ពីសុខភាពបបូរមាត់ ដើម្បីភាពស្រស់ស្អាតគ្រប់លក្ខណៈរបស់អ្នក...។**

តាមពិតទៅបបូរមាត់ គឺជាអវយវៈដែលបានទទួលផលប៉ះពាល់ពីការប្រកបការងារបំពេញភារកិច្ចក្នុងមួយថ្ងៃៗរបស់មនុស្សយើងច្រើនបំផុត ។ ហេតុដូច្នេះហើយអ្នកត្រូវយកចិត្តទុកដាក់ថែរក្សាបបូរមាត់ជាប្រចាំ ។

អ្នកឯកទេសខាងផ្នែកស្បែកបានណែនាំឱ្យចាប់ផ្តើមទទួលស្គាល់ពីធម្មជាតិរបស់ពណ៌បបូរមាត់ជាមុនសិន ទើបថែបំប៉នបបូរមាត់ឱ្យមើលទៅប៉ោងតឹងស្អាត ។



ពណ៌បបូរមាត់តាមធម្មជាតិអាស្រ័យទៅលើជាតិសាសន៍ និងសម្បុរស្បែក ។ អ្នកស្បែកសនឹងមានបបូរមាត់ពណ៌ស៊ីជម្ពូ តែបើសម្បុរស្រគាំបបូរមាត់ក៏ស្រគាំដែរ ដោយទៅតាមលក្ខណៈរបស់គ្រាប់ពណ៌ ។ ថ្វីបើសព្វថ្ងៃនេះអាចប្រើក្រែមធ្វើឱ្យបបូរមាត់មានពណ៌ខ្ចីឡើងបានក៏ដោយ ក៏វាគ្រាន់តែជារឿងបណ្តោះអាសន្នតែប៉ុណ្ណោះ នៅពេលឈប់ប្រើពណ៌បបូរមាត់ក៏ត្រឡប់មករកសភាពដូចដើមវិញ ។ ដូចនេះវិធីងាយៗ ដែលគួរយល់ដឹង គឺបបូរមាត់ក៏ដូចជាស្បែកផ្នែកផ្សេងៗ ដែលត្រូវខ្មៅស្រគាំ ព្រោះត្រូវពន្លឺថ្ងៃដូចគ្នាដែរ ថែមទាំងឆាប់ស្ងួតទៀតផង ។ ដូចនេះ ក្រែមថែស្បែកបបូរមាត់ ឬ Lip-palm ជាវត្ថុចាំបាច់ក្នុងការថែរក្សាសុខភាពស្បែក ដោយអ្នកអាចប្រើ Lip-palm លាបបានទាំងមុនពេល លាបក្រែមបបូរមាត់ ឬតាក់តែងមុខក្រោយពេលបរិភោគអាហារគ្រប់ពេល ។ល។ ការពិសាទឹកច្រើនក៏សំខាន់មិនតិចដែរ ព្រោះជួនកាលបើអ្នកស្ថិតក្នុងស្ថានភាពអាកាសធាតុដែលកោសិកាស្បែកមិនអាចរក្សាជាតិទឹកបានដូចជានៅក្នុងបន្ទប់ម៉ាស៊ីនត្រជាក់ កន្លែងដែលមានអាកាសធាតុស្ងួតហួតហែងសំណើមក្នុងស្បែកនឹងរំហួតចេញអស់ ។ ទង្វើលិទ្ធកេះប៉ះបបូរមាត់ជាញឹកញាប់ជាកត្តាដែលគួរចៀសវាង ព្រោះបើកាន់តែធ្វើច្រើនប៉ុណ្ណានោះ នឹងធ្វើឱ្យមាត់ស្ងួតខ្លាំងឡើងៗតាមនោះដែរ ។ ការបរិភោគផ្លែឈើមិនត្រឹមត្រូវតាមក្បួនក៏ធ្វើឱ្យមានផលប៉ះពាល់បានដូចជាខាំផ្លែឈើដោយមិនបានបកសំបកជាមុនសិន ធ្វើឱ្យជ័រ និងថ្នាំសម្លាប់សត្វល្អិតដែលជាប់នឹងផ្លែឈើប៉ះបបូរមាត់ ឬជួនកាលបបូរមាត់ក៏អាចមានប្រតិកម្មនឹងសារធាតុខ្លះៗក្នុងក្រែមលាបបបូរមាត់ដែរ ។ ដូចនេះប្រសិនបើមានអាការហើមជាពងខ្ទុះថ្លាៗ អាចបញ្ជាក់ពីអាការរងប្រតិកម្ម ។ ដូច្នេះត្រូវប្រញាប់ការប្រើវត្ថុ ដែលកំពុងប្រើភ្លាមៗ ដោយរង់ចាំឱ្យអាការប្រតិកម្មបាត់ស្រឡះសិន (ភាគច្រើនត្រូវចំណាយពេល៧ថ្ងៃ) ទើបងាកមករកមូលហេតុដើមនៃការមានប្រតិកម្មនោះវិញ ៕

# គ្រឿងសំអាងតាមរូបមន្តធម្មជាតិ



ស្ត្រីប្រហែលជាបានដឹងច្បាស់រួចមកហើយថា ទាំងទឹកដោះគោជូរ និងទឹកឃ្មុំមិនមែនគ្រាន់ តែជាអាហារដែលយើងនាំយកមកទទួលទានតែប៉ុណ្ណោះទេ ។ នៅក្នុងទឹកដោះគោជូរ និងទឹកឃ្មុំអាចសំបូរទៅដោយវីតាមីន និងរ៉ែធាតុជាច្រើនសន្ធឹកសន្ធាប់ ដែលមានប្រយោជន៍ចំពោះសុខភាពស្បែកទាំងសារជាតិអង់ទីអុកស៊ីឌែន វីតាមីន B អាស៊ីដអាមីណូ ដែលមានប្រយោជន៍ចំពោះសុខភាព និងជួយពន្យារការចុះខ្សោយនៃកោសិការបស់យើងអាចនាំយកគុណប្រយោជន៍ទាំងអស់នេះមកប្រើក្នុងការបំប៉នស្បែកមុខបាន ។ ក្នុងនោះមានចាប់តាំងពីការសំអាតស្បែកបង្ហាប់រន្ធរោមបំប៉នស្បែកឱ្យមានសំណើម និងការពារការកើតស្នាមជ្រីវជ្រួញ ។

វិធីនេះក៏មិនពិបាកទាល់តែសោះ ដោយប្រើទឹកដោះគោជូរមួយពែងផ្សំជាមួយ និងទឹកឃ្មុំស្ទុ២ស្លាបព្រាកាហ្វេ ។ សំរាប់មនុស្សដែលមានស្បែកខ្លាញ់គួរបន្ថែមក្រូចឆ្មារចូលបន្តិចដើម្បីជួយផ្តិតយកជាតិខ្លាញ់ដែលលើសផ្សំឱ្យចូលគ្នាបានល្អ រួចនាំមកបិទបំពោកឱ្យពេញផ្ទៃមុខ និងដើមក ។ លើកលែងតែបរិវេណជុំវិញត្របកភ្នែក ទុកចោលរយៈពេល៥នាទី រួចលាងចេញដោយទឹកស្អាតបន្ទាប់មកជូតផ្តិតឱ្យស្ងួត ។ គួរអនុវត្តបែបនេះ១សប្តាហ៍ ១-២ដង ។ រូបមន្តមួយនេះក្រៅពីជួយសំអាតស្បែកមុខហើយអាស៊ីឡេកទិកនៅក្នុងទឹកដោះក៏អាចជួយបំប៉នស្បែកឱ្យទន់ស្អាត ចំណែកទឹកឃ្មុំវាជួយបង្កើនភាពសំណើមដល់ស្បែកធ្វើឱ្យស្បែកបានស្រស់ក្មេងជាងវ័យមិនចាស់ជ្រីវជ្រួញ ៕




## ក្រុមហ៊ុនធានារ៉ាប់រង
## TOP AUTO INSURANCE AGENCY

នាងខ្ញុំនិយាយភាសាខ្មែរ

AUTO - LIFE - HEALTH - HOME - COMMERCIAL

រថយន្ត -ជីវិត -សុខភាព -គេហដ្ឋាន -ពាណិជ្ជកម្ម

*-Immediate Coverage* *FREE QUOTE* *Instant SR22*
*-Any car, any driver* *LOW RATES* *Why pay more*

-Low Cost. Low Down. Low Monthly Payment
Tickets, accident,DUI=No Problem
- Multiple Car discount
- Good driver discount

• ធានារ៉ាប់រងជូនភ្លាមៗដល់អ្នកបើកបរគ្រប់រូប និងយានយន្តគ្រប់ប្រភេទ
• ចុះថ្លៃជូនអ្នកបើកបរមានសុវត្ថិភាព និងចុះថ្លៃជូនចំពោះរថយន្តច្រើន
• បង់កាត់ខែតិច • ជំរាបតម្លៃជូនជាមុន



Tiffany Prak
Broker/Agent Lic.# 0E44334
(562) 230-5100

**2760 E. Sprint St., Suite 140 • Long Beach, CA 90806**
**Tel: (562) 989-1800 Fax: (562) 989-1899**



## ហាងខ្មែរលក់គ្រឿងបន្លាស់រថយន្ត
## Parts For Less
## Auto Parts & Accessories

**1050 E. Pacific Coast Hwy.**
**Long Beach, CA 90806**

**562-599-6364**

មានលក់គ្រឿងបន្លាស់រថយន្តគ្រប់ប្រភេទសម្រាប់ក្រៅនិងក្នុងស្រុក ។ ទំនិញយើងខ្ញុំលក់តម្លៃសមរម្យ និងធានារកជូនលោកអ្នកនូវទំនិញដែលមិនមានក្នុងហាងយើងខ្ញុំ ។

Complete Foreign & Domestic Parts

**សូមអញ្ជើញដោយមេត្រីភាព!**



សុខភាព

# ប្រការដែលនាំឱ្យអស់កម្លាំងល្ហិតល្ហៃ

ការប្រកបការងារ និងរោគជម្ងឺខ្លះក៏មានចំណែកពាក់ព័ន្ធបង្កឱ្យកើតអាការអស់កម្លាំងល្ហិតល្ហៃនេះដែរ ។ ដូច្នេះដើម្បីការពារ និងទប់ស្កាត់អាការទាំងអស់នេះ គឺលោកអ្នកត្រូវចៀសវាងដែលមានដូចខាងក្រោមនេះ ។



**១-នៅក្បែរឧបករណ៍អគ្គិសនីច្រើនពេក :** ប៉ូលបូក (+) ដែលបានមកពីឧបករណ៍អេឡិចត្រូនិច ឬម៉ាស៊ីនត្រជាក់អាចជំរុញឱ្យកើតអ័រម៉ូនដែល ធ្វើឱ្យយើងអស់កម្លាំងល្ហិតល្ហៃ និងស្រងូតស្រងាត់ ។ វិធីនេះដោះស្រាយដ៏ល្អបំផុត ពុំគួរនៅក្បែរឧបករណ៍ទាំងនេះយូរពេកឡើយ ។

**២-កុំឱ្យស្ងាប :** ការស្ងាប ជាការកើតឡើងតាមធម្មជាតិ ដែលរាងកាយរបស់យើងត្រូវជំរុញឱ្យកម្រើកនូវអារម្មណ៍ឡើងពីការងងុយដេក ។ អ្នកចិត្តវិទ្យាបាននិយាយថា ចលនារបស់ថ្គាមនឹងទៅជំរុញការគាបច្របាច់សរសៃឈាមលើផ្ទៃមុខ ដែលបញ្ជូនឈាមទៅកាន់ខួរក្បាល ហេតុដូច្នេះការទប់ស្ងាបបានក្លាយជាការរាំងស្ទះដល់ចលនាទាំងនេះ ហើយនឹងជំរុញឱ្យអ្នកកាន់តែងងុយដេកខ្លាំងឡើងថែមទៀត ។

**៣-ធូលីនៅត្រង់មាត់បង្អួច :** តាមការស្រាវជ្រាវបានរកឃើញថា ៨៨% នៃផ្ទះទូទៅតែងមានធុះផ្សិតនៅតាមមាត់បង្អួច និងមនុស្សមួយភាគខ្លះមានប្រតិកម្មជាមួយផ្សិតនេះ បង្កធ្វើឱ្យអស់កម្លាំង និងមានអារម្មណ៍ធុញថប់ ។ គួរធ្វើការសម្អាតដោយបោសជូត ឬលាងទឹកសាប៊ូឱ្យបានស្អាតជាប់ជាប្រចាំ ។

**៤-សម្ពាធឈាមទាប :** សម្ពាធឈាមទាប គឺជាមូលហេតុដ៏សំខាន់មួយដែលធ្វើឱ្យអស់កម្លាំងល្ហិតល្ហៃ ។ គ្រូពេទ្យឯកទេសពុំទាន់បានអះអាងពីមូលហេតុនេះឱ្យបានច្បាស់លាស់នៅឡើយទេ ។ ប៉ុន្តែគេជឿជាក់ថាកើតឡើងដោយសារឈាម ទៅចិញ្ចឹមខួរក្បាលមិនគ្រប់គ្រាន់ ។ អាការនេះ គេតែងតែជួបញឹកញាប់បំផុតទៅលើក្រុមមនុស្សដែលមានសម្ពាធឈាមទាប ។ អ្នកជួបបញ្ហានេះ ច្រើនមានអារម្មណ៍ងងឹតមុខពេលក្រោកឡើងភ្លាមៗពីដំណេកអង្គុយ ឬឈររយៈពេលយូរ ។ បើអ្នកមានអាការបែបនេះ គួរ ទៅពិភាក្សាជាមួយគ្រូពេទ្យឯកទេស ។

**៥-មិនបានយកភួយហាលថ្ងៃ :** ជាតិសើមខ្លាំងបានធ្វើឱ្យធូលីលូតលាស់បានល្អ ហើយអាចបង្កធ្វើឱ្យកើតអាការតាមបំពង់ខ្យល់ក្នុងសួត នាំឱ្យដកដង្ហើមស្ទះ និងទទួលទានដំណេកមិនលក់ស្កប់ស្កល់ ។ ផលអាក្រក់របស់វា គឺធ្វើឱ្យអស់កម្លាំងល្ហិតល្ហៃកើតឡើងក្នុងថ្ងៃបន្ទាប់មកទៀត ។ គួរយកភួយទៅហាលសំដិលថ្ងៃឱ្យបានជាប់ជាប្រចាំ ព្រោះនៅពេលអស់សំណើមធូលី និងមេរោគផ្សេងក៏អស់ទៅជាមួយគ្នាដែរ ។

**៦-ទទួលទានអាហារមិនឆ្អែត :** ការស្រេកឃ្លាន និងការទន្ទឹងរង់ចាំអាហារបានធ្វើឱ្យសរីរាង្គកាយផលិតបរិមាណទឹករំលាយអាហារច្រើនកើតឡើង ប៉ុន្តែពេលនោះ បើពុំមានអាហារអ្វីចូលទៅសម្រាប់កិនរំលាយទេ វានឹងធ្វើឱ្យអាការល្ហិតល្ហៃកើតមានឡើងដែរ ។ អ្នកដែលជួបអាការបែបនេះ ច្រើនបំផុតគឺស្ត្រី ហេតុដូច្នេះអ្នកគួររកអ្វីមកទទួលទានទ្រាប់ពោះឱ្យបានឆ្អែតផង មុននឹងចូលដំណេកនេះ ។

**៧-រាងកាយមានបញ្ហា :** ទោះបីជាការឈឺដើមទ្រូងជាសញ្ញាដ៏សំខាន់បញ្ជាក់ប្រាប់ពីរោគបេះដូង ប៉ុន្តែសម្រាប់ស្ត្រី សញ្ញានោះអាចជាភាពខ្សោយផ្នែកកម្លាំងទៅវិញទេ ។ ស្ត្រីខ្លះដែលមានរោគប្រចាំខ្លួន ដូចជារោគស្ត្រីដេកមិនលក់ ភាពតឹងតែងអារម្មណ៍ការទុក្ខព្រួយលំបាកក៏នាំឱ្យកើតអាការអស់កម្លាំងកំហែងដូចគ្នា ។

**៨-ខ្នើយចាស់ពេក :** បើសិនខ្នើយរបស់អ្នកទន់ជ្រាយមិនរឹងល្អដូចកាលពីមុន វានឹងធ្វើឱ្យករបស់អ្នកមិនរាបស្មើល្អ តាមដងខ្លួនដែលមិនត្រឹមតែធ្វើឱ្យសាច់ដុំរឹងតឹងទេ ថែមទាំងធ្វើឱ្យការទទួលទានដំណេកពេលនោះមិនលង់លក់ និងរួមទាំងការដកដង្ហើមមិនស្រួលទៀតផង ។

**៩-មិនហាត់ប្រាណ :** ក្រុមអ្នកស្រាវជ្រាវបានរកឃើញថា អ្នកដែលធ្វើការហាត់ប្រាណយ៉ាងតិចបំផុត ២០នាទី ទោះបីជាក្នុងមួយអាទិត្យមួយលើកក៏ដោយ ក៏តែងទទួលអារម្មណ៍អស់កម្លាំងល្ហិតល្ហៃតិចជាងអ្នកដែលមិនហាត់ប្រាណសោះ ៣០ភាគរយផងដែរ ។ បើសិនអ្នកយល់ឃើញថា ការហាត់ប្រាណជារឿងពិបាកខ្លាំង សុំឱ្យអ្នកបែរមកចាប់អារម្មណ៍ទទួលទានបន្លែនិងផ្លែឈើបន្ថែមវិញ ។ អ្នកដែលទទួលទានបន្លែច្រើនក្នុងមួយថ្ងៃអាចកាត់បន្ថយអាការល្ហិតល្ហៃ បន្ទាប់មកធ្វើឱ្យយើងលង់លក់ស្កប់ស្កល់ ៕


MODERN FABRIC & SHOES

-ហាងយើងខ្ញុំមានលក់ ក្រណាត់ប៉ាក់ ស្បែកជើង សំលៀកបំពាក់
-ទទួលកាត់សំលៀកបំពាក់គ្រប់ម៉ូតសំរាប់បុរសនិងស្ត្រី
-សំអាងការតាមបែបបូរាណនិងសម័យថ្មីនិយម

សូមស្វាគមន៍ដោយក្តីរីករាយ!









1636 E. ANAHEIM STREET LONG BEACH, CA 90813
Tel: (562) 599-3333 • (562) 599-3237

# LAW OFFICE OF BOROTH CHAY

# ការិយាល័យមេធាវី



▸មេធាវីខ្មែរពូកែក្តីក្តាំនូវករណីគ្រោះថ្នាក់ចរាចររថយន្ត
◆អន្តោប្រវេសន៍ (ធានាប្តីប្រពន្ធ, គូដណ្តឹង, បងប្អូន) ◆ច្បាប់គ្រួសារ
◆បណ្តឹងលែងលះ ◆ប្រាក់ចិញ្ចឹមកូន ◆ឧក្រិដ្ឋកម្ម ◆រដ្ឋប្បវេណី ◆ច្បាប់ក្ស័យធន
▸បើមិនឈ្នះក្តី គឺមិនគិតកម្រៃ .ពិគ្រោះយោបល់ ឬពិភាក្សាមិនគិតថ្លៃ
▸ករណីប្តឹងផ្តល់នឹងផ្តល់ចម្លើយជូនលោកអ្នក ថាតើបណ្តឹងរបស់លោកអ្នក មានសង្ឃឹមឈ្នះឬយ៉ាងណា? តើគួរធ្វើការប្តឹងផ្តល់ដែរឬទេ? ។



**Up to 50% of Settlement to Clients**

▸Bankruptcy ▸Family Law ▸Dissolution of Marriage
▸Child and Spousal Support ▸Immigration
▸Family Sponsor Petition ▸Auto Accident
▸Low Contingency ▸No Recovery ▸No Fee.

**Personal Injury:**

Auto Accident Free Consultation
How strong is your case?
Should you file a claim?

We'll answer your questions!

**Bother Legal Representations:**

Family Law: Dissolution of Marriage,
Spousal and Child Support Bankruptcy
Immigration Law: Family sponsored petition

**5199E. Pacific Coast HWY, Ste. 206, Long Beach, CA 90 804**
**Tel: (562) 961-0142 .(562) 453-5898**

# នាយកដ្ឋានមាតុភូមិ

## មជ្ឈមណ្ឌលអក្សរសាស្ត្រខ្មែរ

*Khmer Education Center*

*www. mietophoum. com*



## សេចក្តីជូនដំណឹង!

*នាយកដ្ឋានមាតុភូមិមានសេចក្តីរីករាយ សូមជំរាបជាសាធារណៈជូនចំពោះលោក លោកស្រី និងបងប្អូនទាំងអស់ថា: យើងខ្ញុំមានបើកថ្នាក់បង្រៀនអក្សរខ្មែរសម្រាប់សិស្សានុសិស្សទូទៅ ចាប់តាំងពីខែតុលា ឆ្នាំ២០០៧ នេះតទៅ ។*

*អាស្រ័យដូចបានជំរាបខាងលើ សូមលោក លោកស្រី មេត្តានាំកូនទៅចុះឈ្មោះចូលរៀនឲ្យបានរួសរាន់ នៅ:*

2517 E. Anaheim Street • Long Beach, CA 90804
Tel: (562) 438-8602










យុន ហេង គឺជាផ្សារខ្មែរដ៏ធំមួយតាមផ្លូវអាណាហែម មានលក់ទំនិញគ្រប់មុខ៖
- សាច់ បន្លែ ផ្លែឈើស្រស់ៗ
- អាហារស្ងួតនិងម្ហូបកំប៉ុងមកពីអាស៊ី
- និងមានលក់ម្ហូបឆ្អិនស្រាប់ៗផងដែរ
- ហើយនឹងមានលក់បាច់ផ្កាសម្រាប់ពិធីបុណ្យនានា ។

**ទោះនៅទីណា**
**សូមកុំភ្លេចផ្សារ**

# យុន ហេង

**915 E. Anaheim Street**
**Long Beach, CA 90813**

**(562) 599-7240**

# ហាងខ្មែរផលិតនំក្រួហ្សង់

-មានគុណភាពទុកបាន៣០ថ្ងៃ
-ដឹកជញ្ជូនដោយមិនគិតថ្លៃពីថ្ងៃចន្ទ-សុក្រ
-ហាងយើងខ្ញុំមានលក់ដុំតែប៉ុណ្ណោះ
-អ្នកទិញត្រូវឲ្យដឹងមុន១ថ្ងៃ

## C & B CROISSANTS

WHOLESALE ONLY

ORDER BY PHONE:
(562) 495-5713
(800) 974-3888
Cell: (562) 607-3258
Fax: (562) 495-7544

FREE DELIVERY

We guarantee our products up to 30 days. Order must be made 1 day in advance.

WHOLE SALE ONLY





| Item | Net Wt Each | Packaging | Price/Package |
|---|---|---|---|
| Butter Croissant | 4.50 oz | 50 | $17.00 |
| Triangle Croissant | 5.00 oz | 50 | $17.00 |
| Square Croissant | 5.00 oz | 50 | $17.00 |
| Cream Cheese Croissant | 6.00 oz | 50 | $22.00 |
| Blueberry Cream Cheese Croissant | 6.oo oz | 50 | $22.00 |
| Strawberry Cream Cheese Croissant | 6.00 oz | 50 | $22.00 |
| Raisin Cinnamon Croissant | 6.00 oz | 50 | $22.00 |
| Raisin Custard Croissant | 6.00 oz | 50 | $22.00 |
| Apple Croissant | 6.00 oz | 50 | $22.00 |
| Chocolate Croissant | 6.00 oz | 50 | $22.00 |
| Chocotate Cream Cheese Croissant | 6.00 oz | 50 | $22.00 |
| Pineapple Cream Cheese Croissant | 6.00 oz | 50 | $22.00 |

1339 W. Gaylord Street• Long Beach, CA 90813

# ព្រះសង្ឃ និងប្រព័ន្ធ Internet !


ព្រះសមណសិស្ស ឆាន ឈូ នាឆ្នាំ១៩៧០

●●●សំណួរនៅត្រង់ថា តើព្រះសង្ឃមានកំហុសឆ្គងប្រាសចាកពីវិន័យក្រិត្យក្រមនៃព្រះពុទ្ធបញ្ញត្តិ ឬព្រះត្រៃបិតកដែរឬទេ អីនៅពេលដែលព្រះសង្ឃប្រើប្រាស់ប្រព័ន្ធ Internet ដើម្បីសិក្សាស្រាវជ្រាវនោះ? ។

-តទៅនេះ គឺជាកិច្ចសម្ភាសន៍រវាងខ្មែរប៉ុស្តិ៍ និងអតីតសមណសិស្សសាលាបាលីខេត្តបាត់ដំបងលោក ឆាន ឈូ ដែលបានបួសរៀនជាសង្ឃជាង៦ព្រះវស្សានោះ ដែលមានអត្ថន័យដូចខាងក្រោម :

-**ខ្មែរប៉ុស្តិ៍ :** តើមានពុទ្ធឱវាទ ឬគម្ពីរព្រះត្រៃបិតកមានចែងថា ព្រះសង្ឃមិនអាចប្រើប្រាស់ប្រព័ន្ធ Internet បានទេ ដោយក្នុងន័យថា ប្រាសចាកពីវិន័យសង្ឃ?

-**ឆាន ឈូ :** គ្មានទេបាទ ដោយកាលដែលព្រះពុទ្ធលោកគង់នៅជាធរមាននៅឡើយនោះ នៅមិនទាន់មានប្រព័ន្ធ Internet ទេបាទ ។ ដូច្នេះពុទ្ធបញ្ញត្តិក៏គ្មានដែរ ។

-**ខ្មែរប៉ុស្តិ៍ :** តើព្រះសង្ឃចាំបាច់ណាស់ទៅសំរាប់ការប្រើប្រាស់ប្រព័ន្ធ Internet ដើម្បីមើល ឬសិក្សាទេ ក្នុងខណៈដែលសង្គមពិភពលោកកំពុងតែវិវឌ្ឍន៍ទូវ ផ្នែកបច្ចេកវិទ្យាទំនើបនោះ? ។

-**ឆាន ឈូ :** ខ្ញុំយល់ថា ព្រះសង្ឃដែលឧស្សាហ៍សង្វាតការសិក្សាមានការចាំបាច់ណាស់ក្នុងការប្រើប្រាស់ប្រព័ន្ធ Internet ព្រោះផ្លូវការមួយនេះ គឺជាត្រីះ ឬជាជំនួយការដ៏សំខាន់មួយសំរាប់សិក្ខាកាមគ្រប់រូប ទាំងផ្លូវលោកទាំងផ្លូវសាសនា ។

-**ខ្មែរប៉ុស្តិ៍ :** តើព្រះសង្ឃសមទំនងនឹងធ្វើការសិក្សាបន្តទៀតទេ ក្នុងនាមជាអ្នកបួសដើម្បីជួយអភិវឌ្ឍន៍សង្គមដូចជា សាសនាគ្រីស្ទ៍ន បុព្វជិតពួកគេតែងយក តួនាទីពីការរៀនសូត្រទៅជួយប្រជាជនគេ? ។

-**ឆាន ឈូ :** ខ្ញុំយល់ថានៅសហរដ្ឋអាមេរិកនេះ ព្រះពុទ្ធសាសនាជាសាសនាតូចតាចណាស់ បើប្រៀបធៀបទៅនឹងសាសនាត្រីះ ។ ដូច្នេះព្រះសង្ឃគ្រប់ព្រះអង្គ បើមានឱកាសលោកគួរតែខំប្រឹងប្រែងស្រាវជ្រាវសិក្សាបន្ថែមទៀត អំពីព្រះពុទ្ធសាសនា ដើម្បីផ្សព្វផ្សាយព្រះពុទ្ធសាសនារបស់យើងឱ្យបានរីកចំរើនដុះដាលជ្រួតជ្រាបកាន់តែខ្លាំងឡើង ។

-**ខ្មែរប៉ុស្តិ៍ :** នៅសង្គមអាមេរិកាំងគេសង្កេតឃើញសាសនាព្រះពុទ្ធ ហាក់មានការផ្សព្វផ្សាយសាសនាខ្លួនតាមរយៈព្រះសង្ឃនៅមានកំរិតស្តួចស្តើង តើយើងគួរមានការផ្សាយដំណឹងតាមប្រព័ន្ធទំនើប Internet ឱ្យមានភាពទូលំទូលាយទេ? ។

-**ឆាប ឈូ :** ដូចខ្ញុំបានជម្រាបនូវសំណួរមុននេះដែរថា ការផ្សព្វផ្សាយព្រះពុទ្ធសាសនាកត្តាធំៗមានដូចជា ព្រះសង្ឃត្រូវមានការចេះដឹងជ្រៅជ្រះពីព្រះពុទ្ធសាសនា រក្សាវិន័យខ្ជាប់ខ្ជួន កុំធ្វេសប្រហែស កុំធ្វើឱ្យព្រះពុទ្ធសាសនិកជនអសទ្ធា (អស់ជំនឿ) ត្រូវសិក្សាបន្ថែមចំណេះដឹងឱ្យបានច្រើនបំផុត ដែលអាចធ្វើទៅបាន ដើម្បីឱ្យមានការងាយស្រួលក្នុងការឃោសនាអធិប្បាយពន្យល់ដល់មនុស្សទូទៅ ដែលចង់ដឹង ចង់យល់ពីព្រះពុទ្ធសាសនាឱ្យបានច្បាស់ពន្យល់ឱ្យត្រូវឱ្យចំៗ កុំស្រស្រពិចស្រពិលកុំស្មាន ។

-ដូច្នេះ Internet ជាប្រព័ន្ធផ្សព្វផ្សាយព្រះពុទ្ធសាសនាមួយសំខាន់ណាស់ ព្រោះក្នុងសហរដ្ឋអាមេរិកនេះមនុស្សមមាញឹកនឹងការងារខ្លាំង គេមិនសូវមានពេលវេលាទៅកាន់វត្តអារាមប៉ុន្មានទេ ដូច្នេះគេអាចស្រាវជ្រាវសិក្សានូវព្រះពុទ្ធសាសនាខ្លះៗតាមប្រព័ន្ធ Internet ដែលព្រះសង្ឃមានតួនាទីរៀបចំកែច្នៃ ។ ខ្ញុំយល់ថា មិនគួរហាមប្រាមព្រះសង្ឃមិនឱ្យប្រើប្រាស់ Internet ទេ បើយើងយល់ថា ព្រះ-សង្ឃប្រើ Internet យូរៗទៅលោកអាចប្រើ


ឆាន ឈូ ឆ្នាំ ២០០៦

ឬមើលអ្វីខុសពីកិច្ចការរបស់សង្ឃ ដែលធ្វើឱ្យប៉ះពាល់សង្ឃវិន័យត្រង់ចំណុចនេះត្រូវដែរ ។ ប៉ុន្តែយើងគួរយល់ថា ព្រះសង្ឃមិនមែនកាន់វិន័យបានល្អគ្រប់អង្គនោះទេ ទោះបីនៅទីណាក៏ដោយ ពីជំនាន់ពុទ្ធកាលក៏ដោយ កុំថាឡើយជំនាន់បច្ចុប្បន្នកាលនេះ យើងត្រូវគិតថា បើសង្ឃអង្គណាប្រព្រឹត្តិមិនគប្បីសង្ឃអង្គនោះនឹងទទួលទោសបាបកម្មនូវអំពើដែលលោក បានប្រព្រឹត្តិទៅចុះ ដោយអំពើអាក្រក់ទាំងនោះថ្ងៃណាមួយនឹងលេចចេញឱ្យពុទ្ធបរិស័ទដែលនៅក្បែរលោកបានដឹង-មិនខាន ។ ក្នុងលោកយើងនេះ គ្មានអ្វីជាអាថិកំបាំងទេ ពេលនោះលោកមិនត្រឹមតែទៅទទួលផលកម្មនូវឯលោកកុត្តរៈជាតិទេ តែលោកនឹងត្រូវទទួលផលកម្មដ៏អាម៉ាស់នៅក្នុងលោកីយ៍នេះផងដែរ ។ ហើយព្រះសង្ឃអង្គនោះក៏ដោយ បើលោកពេញទៅដោយបច្ចាទិដ្ឋិក្នុងព្រះពុទ្ធសាសនាបែបនេះ លោកគួរតែលាចាកសក្ខាបទទៅលោកអស់និស្ស័យជាព្រះសង្ឃហើយ កុំនៅបំផ្លាញព្រះពុទ្ធសាសនាដ៏តូចខ្ចីរបស់យើងក្នុងសហរដ្ឋអាមេរិកនេះ ។

-**ខ្មែរប៉ុស្តិ៍ :** ក្នុងនាមលោកជាអ្នកបួសរៀនធម៌អាជាង៦ព្រះវស្សា តើលោកយល់ឃើញយ៉ាងណាពីវិស័យព្រះពុទ្ធសាសនានៅក្រៅប្រទេស និងត្រូវនាំគ្នាធ្វើយ៉ាងណា ដើម្បីឱ្យពុទ្ធបរិស័ទ ឬព្រះសង្ឃរួមសាមគ្គីគ្នាក្នុងការទ្រទ្រង់ព្រះពុទ្ធសាសនាបញ្ចៀសរឿងអាស្រូវក្នុងផ្លូវព្រះពុទ្ធសាសនា ។

-**ឆាប ឈូ :** វត្តអារាម ព្រះសង្ឃរួមគឺ ព្រះពុទ្ធសាសនាក្នុងសហរដ្ឋនេះ មិនទាន់មានប្រព័ន្ធដឹកនាំដូចនៅស្រុកខ្មែរទេ គឺយើងគ្មានក្រសួងធម្មការ គ្មានសង្ឃ នាយក គ្មានមេគណ អនុគណទេ គឺមានតែចៅអធិការវត្តតែប៉ុណ្ណោះ រីឯវត្តខ្លះគ្មានភិក្ខុសង្ឃបួនព្រះអង្គគង់ចាំព្រះវស្សាផង ។ ដូច្នេះឃើញថា មានការលំបាកតែទោះជាយ៉ាងណាក៏ដោយ ឃើញថាព្រះពុទ្ធសាសនារបស់យើងមានការរីកចំរើនជាបង្គួរដែរ ។

សំណួរសួរថា ធ្វើយ៉ាងណាអោយពុទ្ធបរិស័ទ និងព្រះសង្ឃរួមសាមគ្គីគ្នាបញ្ចៀសរឿងអាស្រូវផ្សេងៗទាំងឡាយនោះ គឺជារឿងមួយធំណាស់ ពិបាកឆ្លើយណាស់វែងណាស់តែខ្ញុំសូមឆ្លើយខ្លីៗថា កាត់យកភាគតូចមកឆ្លើយមួយជ្រុងចុះបាទ ។

-តែមួយៗមានព្រះគ្រូចៅអធិការជាធំបន្ទាប់មកមានព្រះគ្រូសូត្រស្តាំ ហើយគ្រូសូត្រឆ្វេង និងភិក្ខុសាមណេរបន្តបន្ទាប់ ។ ដូច្នេះភិក្ខុ ដូច្នេះកិច្ចការរបស់សង្ឃត្រូវប្រគល់ឱ្យសង្ឃលោកចាត់ចែង យើងជាអាចារ្យជាគណៈកម្មការត្រូវធ្វើតែភារកិច្ចរបស់យើងបានហើយ ហើយត្រូវរងចាំបំរើបទបញ្ជាតាមព្រះគ្រូចៅអធិការវត្តជានិច្ចជាកាល អ្វីក៏ដោយដែលជារបស់ចុះក្នុងបញ្ជីវត្តត្រូវនៅក្រោមការកាន់កាប់ថែរក្សារបស់ព្រះគ្រូចៅអធិការ លើកលែងតែលោកប្រគល់ទៅអោយគណកម្មការណាម្នាក់កាន់កាប់ជំនួសនោះទើបបាន ។ ហើយបើចៅអធិការលោកត្រូវការសេចក្តីរាយការណ៍ត្រូវទូលលោកអោយបានច្បាស់ អោយមានបញ្ជីក្រដាស់ស្នាមដោយគ្មានស្រពិចស្រពិលឡើយ ។ (តនៅទំព័រទី២៩)

## តុលាការជាវញ្ជ៊ន

ឱ! ឱ ភ័ព្វព្រេងជាតិខេមរា
ធ្លាប់មានជាតិសាសន៍ល្អប្រពៃ
ពីដើមជាតិខ្មែរតែងបានសុខ
មានរិទ្ធិអំណាចហើយទៀតត្រង់
ក្រោយមកជនជាតិជិតខាងខ្មែរ
បាត់អស់ស្មារតីស្នេហាជាតិ
មិនយូរប៉ុន្មានមានខ្មែរក្បត់
ទៅជាតិដទៃធ្វើព្រងើយ
ពេលបានអំណាចកោងកាចណាស់
ធ្វើបាបជាតិឯងគ្មានឥតខ្លាច
ជីវិតជាតិខ្មែរសែនអភ័ព្វ
ពីមេដឹកនាំគ្រប់ស្រទាប់
មានមេដឹកនាំសម័យមួយ
ខ្មែរជិតបួនលានត្រូវក្សិណក្ស័យ
បានកាន់អំណាចយ៉ាងសប្បាយ
បក្សពួកលក់ក្បាល លក់មាយាទ
ចែកមុខតំណែង ចែកការងារ
ធ្វើចិត្តឃោរឃៅ ហើយកោងកាច
ព្រលឹងជាតិខ្មែរត្រូវរងទុក្ខ
នៅលើរូបកាយធ្ងន់សែនទ្វី
ចៅក្រមតុលាការត្រៀមខ្លួន
ក្នុងការកាត់ទោសជនចិត្តខ្លា
តុលាការនេះមានសុទ្ធតែ
ត្រូវតែស្វែងរកក្តីសុចរិត
តុលាការនេះមិនត្រូវខ្លាច
លើក្តីយុត្តិធម៌ជាមូលដ្ឋាន
ធ្វើអោយជាតិខ្មែរមានសង្ឃឹម
បានយុត្តិធម៌ដោយពេញមុខ
ដូច្នេះជីវិតជនជាតិខ្មែរ
សូមអោយចៅក្រមសហការ
ចាប់យកអោយបានមេកំពូល
ពីបទឧក្រិដ្ឋពិតពេកក្រៃ
ខ្មែរចិត្តស្លូតត្រង់ សូមបន់ស្រន់
កិត្តិយសជាតិខ្មែរអោយទៅតាម
សូមជួយជាតិខ្មែរអោយគង់វង្ស
ជាជាតិពូជសាសន៍ខ្មែរអង្គរ
មិនត្រូវមានជាតិសាសន៍ដទៃ
ភ្លេចគិតជាតិខ្មែរថាខ្មែរប្រាជ្ញ
សូមជួយការពារខ្មែរស្លូតត្រង់
ជាខ្មែរស្នេហ៍ជាតិហ៊ានស៊ូក្ស័យ
មាតុភូមិខ្មែរពិត មិនត្រូវក្លាយ
សូមបានស្ថិតស្ថេរ ចិរយូរលង់

ជាជាតិថ្លៃថ្លាមានទឹកដី
ជាតិស្លូតបូតក្រៃមានពូជពង្ស ។
រស់នៅពេញមុខល្អត្រចង់
ជួយគ្នាទ្រទ្រង់តំកើងជាតិ ។
ចិត្តចង់បង្វែរអោយខ្មែរឃ្លាត
ហើយចង់ពិឃាតអោយខ្មែរខ្សោយ ។
ភ្លេចជាតិប្រាកដលក់ក្បាលអោយ
រួចស្រេចអស់ហើយបានអំណាច ។
ហើយតាំងព្រលះដោយអង់អាច
ដូចចិត្តបីសាច កាច់សម្លាប់ ។
មានមកតាមជាប់ជាលំដាប់
ប្រព្រឹត្តយ៉ាងខ្ជាប់ដល់សព្វថ្ងៃ ។
ចិត្តពុករលួយតែងប្រល័យ
រួចហើយដោះដៃថាស្នេហ៍ជាតិ ។
ក្លេងក្លាងក្លាកក្លាយក្នុងក្រុមញាតិ
បក្សពួកព្រោងព្រាតចែកអំណាច ។
ចែកលុយទ្រព្យា ចែកគ្មានខ្លាច
ដូចព្រាយបីសាចសែនអប្រិយ៍ ។
ក្រៀមក្រំដូចផ្ទុកភ្នំពីរបី
រងចាំមើលថ្ងៃកាត់ទោសា ។
ប្រើតាមច្បាប់ក្បួនល្អសោភា
ដែលបានប្រហារជាតិខ្មែរពិត ។
ចៅក្រមយល់ខ្សែបទឧក្រិដ្ឋ
ជួយដល់ជីវិតខ្មែររាប់លាន ។
ត្រូវប្រើអំណាចមិនបំពាន
អោយខ្មែរគ្រប់ប្រាណបានក្តីសុខ ។
បានល្អត្រូវត្រឹមផុតចាកទុក្ខ
បានរស់មានស្រុកមានកិត្យា ។
គ្រប់គ្នាត្រូវតែតាំងសទ្ធា
នៅក្នុងចេតនាល្អប្រពៃ ។
ក្រហាមអោយចូលមកកាត់ក្តី
ដោយសារស្នាដៃប្រឡាក់ឈាម ។
សូមព្រះមានបុណ្យលើកតាំងនាម
ច្បាប់បានប្រាប់ប្រាមយុត្តិធម៌ ។
ស្ថិតស្ថេរយូរលង់ជាប់នៅល្អ
មានរិទ្ធិបវរឈរអង់អាច ។
ចូលមកប្រល័យអោយខ្មែរខ្លាច
ធ្លាប់មានអំណាច មានរស្មី ។
ខ្មែរថែពូជពង្សរៀងរាល់ថ្ងៃ
អោយជាតិខ្មែរថ្លៃបានគង់វង្ស ។
បែកបាក់ខ្ចាត់ខ្ចាយបាត់ពូជពង្ស
ជាតិខ្មែរត្រចង់តទៅអើយ ។
*សូមអរគុណ !*




# លិខិតឆ្លើយបំភ្លឺចំពោះលោក ពៅ សាវន និង ពៅ វ៉ែន

-សមាជិកគណៈកម្មការវត្តវិប្បសនារាម ហៅវត្ត អាយរ៉ាប់ មានឈ្មោះលោក វ៉ែន ពៅ និង ពៅ សាវន បានកើតទុក្ខមិនសុខចិត្តនឹងការផ្សាយរបស់កាសែតខ្មែរប៉ុស្តិ៍ឆ្នាំទី១ លេខ ៥ ថ្ងៃទី១០-២៥ខែធ្នូ ឆ្នាំ២០០៧ ក្នុងទំព័រទី៧ ក្រោមចំណងជើងថា **"អំណាចលុយនាំភាពវឹកវរនៅវត្តវិប្បសនារាម"** ដោយលោកទាំងពីរបានបដិសេធថា ជារឿងមិនពិតនៃការបរិយាយក្នុងអត្ថបទទាក់ទងទៅនឹងបញ្ហាបួនចំណុច ដែលតម្រូវឱ្យខ្មែរប៉ុស្តិ៍ធ្វើការកែតម្រូវ ដូចជាការចោទប្រកាន់ថា លោក ពៅ វ៉ែន និង លោក ពៅ សាវន ជាកូនមិនបង្ហាញមុខជាសាធារណៈ ដើម្បីបំភ្លឺដល់ការចោទប្រកាន់របស់ពុទ្ធបរិស័ទ។ **ចំណុចនេះការិយាល័យនិពន្ធកាសែតខ្មែរប៉ុស្តិ៍សូមបញ្ជាក់ថា** កាលពីថ្ងៃទី២ ធ្នូ ២០០៧ ក្រុមពុទ្ធបរិស័ទបានទៅចោទសួរចំពោះបញ្ហារឿងរ៉ាវគណៈកម្មការពុទ្ធិកសមាគមវត្តវិប្បសនារាមរំលោភលក្ខន្តិកៈមិនបានបោះឆ្នោតមក១១ឆ្នាំហើយ និងចោទប្រកាន់រឿងរ៉ាវអាស្រូវលុយកាក់ ដែលក្នុងឱកាសនោះ យើងឃើញមានវត្តលោកអាចារ្យ កែប ឆែប តែម្នាក់ដោយខ្មែរប៉ុស្តិ៍បានសួរនាំពីបញ្ហាចោទប្រកាន់របស់ពុទ្ធបរិស័ទពីបញ្ហាលុយ ត្រូវលោកអាចារ្យ ឆែប ប្រាប់ថា គណៈកម្មការគ្រប់គ្រងលុយកាក់បានល្អណាស់ ដោយគាត់បានពោលថា ជិតឈានទៅសង់ព្រះវិហារទៀតផង ដោយគ្មានបាត់លុយកាក់អ្វីមួយសេនទេ ។ បើចង់ច្បាស់សូមសួរទៅប្រធាន ពៅ សាវន ›ទៅ នឹងដឹងរឿងហើយ ។ ត្រង់បញ្ហានេះខ្មែរប៉ុស្តិ៍ព្យាយាមទូរស័ព្ទទៅលោក ពៅ សាវន ជាច្រើនលើកច្រើនសារ ប៉ុន្តែទូរស័ព្ទមិនត្រូវបានលោកលើក ឬហៅតបតវិញ ក្នុងបំណងសុំធ្វើការសំភាសន៍ឱ្យមានព័ត៌មាននៃការសរសេរមានតុល្យភាពនៃដំណឹង ។ ហើយក្នុងអត្ថបទនោះអ្នកនិពន្ធ ក៏បានភ្ជាប់ដាក់ក្នុងការសរសេររបស់ខ្លួនពីការមិនអាចទាក់ទងបាន ដើម្បីសុំចម្លើយផងដែរ ។ ហើយចំណុចទី២ ត្រង់ន័យថា កែប ឆែប , ពៅ វ៉ែន និង ពៅ សាវន មានការចំណាយលុយវត្តខុសប្រក្រតី និងចោទថា អ្នកទាំងបីនាក់ប្រើអំណាចផ្តាច់ការគំរាមកំហែងព្រះសង្ឃជាមួយមិនគោរពតាមលក្ខន្តិកៈធ្វើប្រធានខុសច្បាប់ជាង១១ឆ្នាំនោះ ។ ការិយាល័យនិពន្ធក៏សូមបំភ្លឺថា នេះមិនមែនជាសំណេរដោយមតិឬការបញ្ចេញយោបល់របស់អ្នកកាសែតទេ គឺជាប្រភពពីប្រជាជន ដែលចោទប្រកាន់ពីបញ្ហានេះ ។ និងបញ្ហាការគេងបន្លំពន្ធដារ(TAX)ជាដើមនោះ ។

-ដែលបញ្ហានេះកាសែតខ្មែរប៉ុស្តិ៍មានការសោកស្តាយចំពោះថ្ងៃព្រឹត្តិការណ៍នៃការតវ៉ារបស់ពុទ្ធបរិស័ទនៅក្នុងវត្តចំពោះមុខព្រះសង្ឃកំពុងឆាន់ នាថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលមានពុទ្ធបរិស័ទនាំគ្នាទាញមេក្រូនិយាយចោទប្រកាន់រិះគន់អស់លោកខាងលើមិន ដែលមិនបានបង្ហាញវត្តមាន គឺជាការពិបាករបស់អ្នកកាសែតយើងក្នុងការស្វែងរកការជួបដើម្បីសុំបំភ្លឺបញ្ហា រហូតធ្វើឱ្យមានការព្រមានពីមេធាវីតំណាងអស់លោកខាងលើដោយយកឈ្មោះក្នុងនាមជាគណៈកម្មការពុទ្ធិកសមាគមវត្តវិប្បសនារាម ដើម្បីឱ្យកាសែតខ្មែរប៉ុស្តិ៍ ធ្វើការកែតម្រូវក្នុងរង្វង់២១ថ្ងៃ ចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០០៧ នេះតទៅ ។

-ខ្មែរប៉ុស្តិ៍សូមអរគុណចំពោះប្រតិកម្មអស់លោក ដោយភាតរភាពក្នុងការឆ្លើយតបដោយមិត្តភាពក្នុងនាមជា ពុទ្ធសាសនិកម្នាក់ សូមឱ្យអស់លោកជួបតែសេចក្តីសុខក្នុងឱកាសបុណ្យណូអែល និងសួស្តីឆ្នាំថ្មីឆ្នាំសកល ។/

***សូមអរគុណ !***





ស៊ីលលួចមើលឪ


កុំភ័យអូន! ចាក់ឡានរួច ចាំបងចាក់អូនឯងម្តង


អោយតែកន្លែងណាមានទឹកគឺមានត្រីហើយ


ទោះជាពូកែឆែកយ៉ាងណាក៏ចាប់មិនបានដែរលោកគ្រូ


រៀនឱ្យហើយធំឡើងមិនបាច់គេប្រាប់


កាមេរ៉ាខ្ញុំ ច្បាស់ជាងរបស់បងឯងទៅទៀត


ទាល់តែព្រលែងអាក្រៅចេញ ទើបមានអ្នកឆាប់មកជួយ


សៀតកាំភ្លើងគំរាមប្រុសព្រាន


សម្លាញ់ប៉ូវបន្តិចទៅ កុំឱ្យស្លាប់លើបង្គង


ទោះជាយ៉ាងណាក៏មិនអាចរាំងស្នេហ៍យើងបានដែរ ?


ម៉ូតូម៉ាកថ្មីសំរាប់ឡើងភ្លឺស្រែ

Philadephia
Advertising
ទំនាក់ទំនងទូរស័ព្ទលេខ:
(267) 254 87 58


ភោជនីយដ្ឋានឋានសួគ៌ថ្មី
New Paradise Restaurant
1350 EAST ANAHEIM STEET , LONG BEACH ,CA 90813
TEL: (562) 218-0066
NEW PARADISE RESTAURANT
NEW PARADISE RESTAURANT
LIVE SEAFOOD
Magic Show
christmas Eve Party
Mon., Dec.24
New Year Eve Countdown
Mon., Dec. 31 ,2007
For christmas Eve Party Admission $25/person 7 Course Dinner
For New Year Eve Party Admission $35/person 7 course Dinner & Champagne
7 pm - Midnight

First AMERICAN TEAM REALTY, INC ™

ជំនាញឯកទេសជាទីទុកចិត្តនិងស្មោះត្រង់ចំពោះលោក-អ្នក

- ពន្យល់ណែនាំពីកិច្ចការទូទៅដែលទាក់ទងនឹងការលក់, ទិញផ្ទះ, ហាងជំនួញនិងដីធ្លី ។
- បង្ហាញលោក-អ្នកឲ្យយល់នូវពិធីខ្ចីប្រាក់សាងសង់ឬដូរសុំលុយផ្ទះជាដើម ។
- បើលោក-អ្នកមានចម្ងល់ពីការលក់ផ្ទះនិងទិញផ្ទះ សូមអញ្ជើញទាក់ទងខ្ញុំបាទគ្រប់ពេលវេលាតាមអាសយដ្ឋានខាងក្រោម៖





Mr. Monorom Neth
Licensed Realtor
2501 Cherry Ave.,#100 • Signal Hill, CA 90755
Office (562) 427-7765 Ext.333
Cell (562) 483-7333 Fax (562) 427-0767

ALL TRANSMISSION & CLUTCH




(562) 494-6968
2800E .PCH Hwy . Long Beach , CA 90804

HILLSIDE CHIROPRACTIC & REHAB CENTER

• AUTO COLLISION• WORK INJURY• SPORT INJURY




មន្ទីរពេទ្យចាប់សរសៃ

FULL SERVICE TREATMENT

- Personal Injury/Sports Injury
- Work Related Injuries
- Chronic Pain Syndromes
- Customize Rehabilitation Programs
- Wellness Care
- Chiropractic Care
- Physical Therapy
- Massage Therapy
- Complete Physical Exams
- Posture/Body Mechanics
- Pre/Post Operation Care
- Neck and Back School
- Auto Accident Care Specialist
- Athletes - DMV / DOT
- Nutritional Analysis
- Therapy Products

CHIROPRACTIC IS PROVEN EFFECTIVE IN THE TREATMENT OF MANY COMMON AILMENTS INCLUDING....

- Headaches
- Neck Pain
- Back Pain
- Shoulder and Arm Pain
- Leg Pain (Sciatica)
- Carpal Tunnel Syndrome
- Numbness & Tingling
- Joint Stiffness
- Muscle Spasms
- Dizziness
- Disc Herniation
- Scoliosis
- Low Energy
- Stress
- And Many Other Common Health Issues

សូមអញ្ជើញ ដោយមេត្រីភាព

ខ្ញុំ Dr. Rene E. Uong និយាយភាសាខ្មែរ

2760 E. SPRING STREET, SUITE 150, LONG BEACH, CA 90806




PHONE:
562-424-1200
FAX:
562-424-1214




ភោជនីយដ្ឋានសូភី

Sophy's THAI & CAMBODIAN CUISINE

ភោជនីយដ្ឋានជាទីពេញចិត្តរបស់លោក-អ្នក ជាមួយម្ហូប ខ្មែរ-ថៃចំរុះគ្រប់មុខដែលមានរសជាតិឈ្ងុយឆ្ងាញ់ពិសារ ។



សូមស្វាគមន៍!



Mon-Sun 9:00 am - 10:00 pm

3720 E. Anaheim St., Ste 102 • Long Beach, CA 90804
Tel: (562) 494-1763 Delivery is FREE with purchase of $15.00 or More